ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank

# របាយការណ៍ប្រចាំឆ្នាំ
# ២០១១













## ធនាគារដែលបង្កើតនូវអនាគតត្រចះត្រចង់របស់កម្ពុជា







**សាខាប៊ីអេស :** អគារប៊ីអេស មហាវិថីព្រះមុនីវង្ស សង្កាត់មនោរម្យ
ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៦០០
ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៤០០




**ការិយាល័យកណ្តាល :** អគារលេខ ៧៦៧-៧៦៩ មហាវិថីព្រះមុនីវង្ស
សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៥០០
ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៥៤០

**សាខាផ្សារដើមគ :** អគារលេខ ៧៨ មហាវិថីព្រះមុនីរ៉េត សង្កាត់ទួលស្វាយព្រៃ២
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៧០០
ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៧០១







**សាខាទួលគោក :** អគារលេខ ២៤ ផ្លូវលេខ ២៧៣ សង្កាត់ទួលសង្កែ
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ : (៨៥៥) ២៣ ៩៩៩ ០៥០
ទូរសារលេខ : (៨៥៥) ២៣ ៩៩៩ ១៥១

**សាខាសៀមរាប :** អគារលេខ ៤២៣ ភូមិវត្តបូព៌ សង្កាត់សាលាកំរើក
ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ : (៨៥៥) ៦៣ ៩៦៧ ៥០០
ទូរសារលេខ : (៨៥៥) ៦៣ ៩៦៧ ៦០០

**អ៊ីម៉ែល** : service@ppcb.com.kh
**គេហទំព័រ** : www.ppcb.com.kh
**SWIFT:** PPCBKHPP

# ចំណាប់អារម្មណ៍របស់អគ្គនាយក និងនាយកប្រតិបត្តិ

## ធនាគារភ្នំពេញពាណិជ្ជ (PPCB) សូមស្វាគមន៍

## ធនាគារភ្នំពេញពាណិជ្ជ (PPCB) តែងតែនៅជាមួយលោកអ្នកជានិច្ច



ក្នុងឆ្នាំ២០១១សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបង្ហាញពីលទ្ធផលជាវិជ្ជមាន ដោយម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាពល្អ ថ្វីបើផ្នែកខ្លះរបស់ប្រទេសទទួលរងផលប៉ះពាល់ដោយសារទឹកជំនន់ក៏ដោយ។ ប៉ុន្តែ ស្ថិតក្រោមលក្ខខណ្ឌនៃការគ្រប់គ្រងដ៏ត្រឹមត្រូវ និងគោលនយោបាយអនុវត្តពន្ធ និងរូបិយប័ណ្ណដ៏សមស្រប ធ្វើអោយផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា បានកើនឡើងចំនួន ៦.៩ ភាគរយ ក្នុងឆ្នាំ២០១១ ក្នុងនោះវិស័យកសិកម្មបានកើនឡើងចំនួន ១.៤ ភាគរយ វិស័យឧស្សាហកម្មកើនឡើងចំនួន ១៤.១ ភាគរយ វិស័យកាត់ដេរកើនឡើងចំនួន ២១ ភាគរយ និងវិស័យសេវាផ្សេងៗទៀតកើនឡើងចំនួន ៥ ភាគរយ។

នៅក្នុងពេលដំណាលគ្នានេះដែរ វិស័យធនាគារដោយស្ថិតក្រោមការគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ពីធនាគារជាតិនៃកម្ពុជានៅតែមានដំណើរការ និងស្ថិរភាពល្អ ហើយជាលទ្ធផលទំនុកចិត្តលើវិស័យធនាគារបានបន្តរីកចម្រើនគួឱ្យកត់សម្គាល់ដោយទំហំនៃប្រតិបត្តិការក្នុង ឆ្នាំ២០១១ ចំនួនប្រាក់បញ្ញើនៅធនាគារពាណិជ្ជកើនឡើងចំនួន ២០.៤ ភាគរយ និងឥណទានផ្តល់ឱ្យដល់ផ្នែកឯកជនបានកើនឡើងរហូត ៣៣.៥ ភាគរយ នេះបើធៀបនឹងអំឡុងពេលដូចគ្នាក្នុងឆ្នាំ ២០១០។

### សមិទ្ធិផល

ឆ្នាំ២០១១ គឺជាឆ្នាំដែលប្រកបទៅដោយព្រឹត្តិការណ៍ល្អៗ និងជាឆ្នាំដែលប្រកបទៅដោយជោគជ័យគួរឱ្យកត់សម្គាល់សម្រាប់ធនាគារភ្នំពេញពាណិជ្ជ។ លទ្ធផលជាវិជ្ជមានមួយទៀត គឺធនាគាររកប្រាក់ចំណេញសុទ្ធបាន ចំនួន ១.៣ លានដុល្លារ អាមេរិក ដល់ភាគទុនិករបស់យើងដែលមានកំណើន ១៣០% លើសឆ្នាំ២០១០។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអោយឃើញពីការសម្រេចបាននូវភាពជោគជ័យក្នុងការបង្កើនចំណូលនៅអំឡុងការកាត់បន្ថយការចំណាយប្រកបដោយការយកចិត្តទុកដាក់ខ្ពស់។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ទ្រព្យសកម្មសរុបរបស់ធនាគារភ្នំពេញពាណិជ្ជបានកើនឡើងរហូតដល់ ១០២ លានដុល្លារ អាមេរិក ដែលមានកំណើន ៧៥% លើសឆ្នាំ២០១០ ប្រាក់ចំណូលសរុបគឺ ៥.៥ លានដុល្លារ អាមេរិក មានកំណើន ៥២% លើសឆ្នាំ២០១០ ប្រាក់បញ្ញើសរុបមានចំនួន ៦០.៣ លានដុល្លារ អាមេរិក ដែលមានកំណើន ៤៣% លើសឆ្នាំ២០១០ ខណៈឥណទានសរុបមានចំនួន ៤៣.២ លានដុល្លារ អាមេរិក ដែលមានកំណើន ៧៥% លើសឆ្នាំ២០១០។

# ចក្ខុវិស័យសម្រាប់អនាគតកម្ពុជា

យើងជឿជាក់យ៉ាងមុតមាំថាក្នុងឆ្នាំ ២០១២ សេដ្ឋកិច្ចរបស់កម្ពុជា និងមានការកើនឡើងជាបន្តទៀតក្នុងរង្វង់ ៦.៥ ភាគរយ ។ នេះជាឱកាសល្អបន្ថែមទៀតដែលនឹងផ្តល់ផលប្រយោជន៏កាន់តែច្រើនដល់អតិថិជនរបស់យើងព្រមទាំងធនាគារភ្នំពេញពាណិជ្ជផងដែរ ។ ធនាគារភ្នំពេញពាណិជ្ជនឹងបន្តលូតលាស់ដើម្បីក្លាយជាធនាគារពាណិជ្ជឈានមុខគេមួយក្នុងប្រទេសកម្ពុជា។ ដោយផ្អែកលើគោលការណ៏គ្រប់គ្រងប្រកបដោយក្រមសីលធមិរបស់ខ្លួន "ធនាគារភ្នំពេញពាណិជ្ជតែងតែនៅជាមួយលោកអ្នកជានិច្ច "ធនាគារភ្នំពេញពាណិជ្ជបានខិតខំប្រឹងប្រែងដើម្បីឱ្យក្លាយជាធនាគារដ៏សំខាន់មួយសម្រាប់ប្រជាជន និងសហគមន៏របស់ខ្លួនជាមួយនឹងយុទ្ធសាស្ត្រគ្រប់គ្រងផ្សេងៗនិងប្លែកៗគ្នា។ យើងក៏បានបង្កើតបាននូវពិភពពាណិជ្ជកម្មដ៏អស្ចារ្យមួយក្នុងវិស័យហិរញ្ញវត្ថុដែលប្រកបដោយការប្រកួតប្រជែងបំផុត ។ ឆ្លងតាមរយៈការទទួលស្គាល់ជាផ្លូវការពាក់ព័ន្ធនឹងការរីកចម្រើនប្រកបដោយសក្តានុពល និងកំណើននៃទំនុកចិត្តរបស់អតិថិជនមកលើធនាគារភ្នំពេញពាណិជ្ជ យើងកំពុងតែបន្តលូតលាស់ ជាអ្នកដឹកនាំមួយនៃវិស័យឧស្សាហកម្មហិរញ្ញវត្ថុដោយពឹងផ្អែកលើគោលការណ៏នៃការគ្រប់គ្រងប្រកបដោយក្រមសីលធមិ ធនធានមនុស្ស សកម្មភាពជំនួញដ៏សកម្មនិងទំនុកចិត្តរបស់អតិថិជនក្នុងកម្រិតខ្ពស់ ។ ជាងនេះទៅទៀតធនាគារភ្នំពេញពាណិជ្ជធ្វើប្រតិបត្តិការលើសេវាហិរញ្ញវត្ថុ និងផលិតផលចម្រុះដែលបង្កើតបាននូវវិធីមួយដើម្បីរកប្រាក់ចំណូលខ្ពស់តាមរយៈសហគ្រាសហិរញ្ញវត្ថុផ្ទាល់តែមួយ ។

# ការទទួលស្គាល់

ក្នុងនាមក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារភ្នំពេញពាណិជ្ជ យើងខ្ញុំសូមសម្តែងនូវការកោតសរសើរនឹងដឹងគុណដ៏ស្មោះចំពោះភាគទុនិកទាំងអស់ អតិថិជន និងសមាគមពាណិជ្ជកម្មដែលបន្តផ្តល់ការគាំទ្រ ផ្តល់ទំនុកចិត្ត និងភាពជឿជាក់របស់ពួកគេចំពោះការរីកចម្រើន និងសមិទ្ធផលរបស់ធនាគារភ្នំពេញពាណិជ្ជ ។

ក្នុងនាមក្រុមប្រឹក្សាភិបាល យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ចំពោះរាល់ការគាំទ្រ និងការផ្តល់ដំបូន្មានល្អៗ ។

ជាចុងបញ្ចប់ យើងខ្ញុំជឿជាក់យ៉ាងមុតមាំថា ដោយមានការប្តេជ្ញាចិត្តខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងធ្វើការយ៉ាងខ្ជាប់ខ្ជួន ធនាគារភ្នំពេញពាណិជ្ជ នឹងបន្តលូតលាស់ជាលំដាប់ដែលយើងកំពុងរងចាំនូវផលចំណេញនិងការសម្រេចគោលដៅថ្មីៗបន្ថែមទៀត ។

គីម យ៉ាងជីន
អគ្គនាយក និងនាយកប្រតិបត្តិ



# ចក្ខុវិស័យ គោលដៅស្នូល និងបាវចនា

## ចក្ខុវិស័យ

ធនាគារដែលបង្កើតនូវអនាគតដ៏ត្រចះត្រចង់របស់ប្រទេសកម្ពុជា តាមរយៈហិរញ្ញវត្ថុឈានមុខគេ និងទំនុកចិត្ត

## គោលដៅស្នូល

ជាធនាគារមួយក្នុងចំណោមធនាគារល្អបំផុតចំនួន ៥ ក្នុងប្រទេសកម្ពុជា

## បាវចនា

១. បំពេញតម្រូវការរបស់អតិថិជន
២. កែលម្អតម្លៃនៃនិមិត្តសញ្ញា
៣. បង្កើនជាអតិបរិមានូវប្រសិទ្ធភាព

# មាតិកា


| | |
|---|---|
| ចំណាប់អារម្មណ៍របស់អគ្គនាយក និងនាយកប្រតិបត្តិ | ១ |
| ចក្ខុវិស័យ គោលដៅស្នូល និងបាវចនា | ៣ |
| សង្ខេបលទ្ធផលហិរញ្ញវត្ថុ | ៥ |
| រចនាសម្ព័ន (២០១១) | ៧ |
| ក្រុមប្រឹក្សាភិបាល (២០១១) | ៨ |
| ព័ត៌មានរួមរបស់ធនាគារ | ១១ |
| ព័ត៌មានសង្ខេបរបស់ធនាគារ | ១១ |
| ព័ត៌មានរួមរបស់ធនាគារ | ១១ |
| បុគ្គលិករបស់ធនាគារភ្នំពេញពាណិជ្ជ | ១២ |
| សមិទ្ធិផលក្នុងឆ្នាំ ២០១១ | ១៣ |
| គោលដៅយុទ្ធសាស្ត្ររបស់ធនាគារភ្នំពេញពាណិជ្ជសម្រាប់ឆ្នាំ ២០១១-២០១៤ | ១៤ |
| ផលិតផល និងសេវា | ១៦ |
| សេចក្តីផ្តើមរបស់ Hyundai Swiss Financial Group (HSFG) | ២០ |
| សេចក្តីផ្តើមរបស់ SBI Holdings, Inc. | ២១ |
| របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍របស់សវនករឯករាជ្យ (២០១១) | ២២ |
| ធនាគារជាដៃគូរបស់ធនាគារភ្នំពេញពាណិជ្ជ (PPCB) | ១០៤ |
| បណ្តាញសាខា | ១០៥ |




# លទ្ធផលហិរញ្ញវត្ថុសង្ខេប

## ការគូសបញ្ជាក់អំពីហិរញ្ញវត្ថុ

(គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១១)

| | ២០១១ | ២០១០ | ២០០៩ | ២០០៨ |
|---|---|---|---|---|
| **លទ្ធផលប្រតិបត្តិការ (គិតជាពាន់ដុល្លារអាមេរិក)** | | | | |
| ចំណេញមុនពេលបង់ពន្ធ | ១.៦៧៧ | ៧២៨ | ៣៨១ | (៥១៥) |
| ចំណេញសុទ្ធក្រោយពេលបង់ពន្ធ | ១.៣១៣ | ៥៩៤ | ៣៥៩ | (៥១៧) |
| **ទិន្នន័យតុល្យការ (គិតជាពាន់ដុល្លារអាមេរិក)** | | | | |
| ទ្រព្យសកម្ម | ១០២.០៥១ | ៥៨.៣៥១ | ៣៤.០៤៥ | ១៩.២១០ |
| ឥណទាន និងបុរេប្រទាន | ៤២.៨៦២ | ២៤.៤៩៩ | ១២.៦៦០ | ៥.២៨៨ |
| ទ្រព្យអកម្ម | ៦១.៣០២ | ៤២.៩១៤ | ១៩.២០៣ | ៤.៧២៧ |
| ប្រាក់បញ្ញើពីអតិថិជន | ៦០.៣២៦ | ៤២.១០៨ | ១៩.១២៣ | ៤.៦៩៦ |
| ដើមទុន | ៣៩.០០០ | ១៥.០០០ | ១៥.០០០ | ១៥.០០០ |
| មូលនិធិម្ចាស់ហ៊ុន | ៤០.៧៤៩ | ១៥.៤៣៧ | ១៤.៨៤២ | ១៤.៤៨៣ |
| **អនុបាតហិរញ្ញវត្ថុ (គិតជាភាគរយ)** | | | | |
| អនុបាតចំណូលធៀបលើទ្រព្យសកម្ម | ២,០០ | ១,០២ | ១,០៦ | (២,៦៩) |
| អនុបាតចំណូលធៀបលើមូលនិធិម្ចាស់ហ៊ុន | ៦,១៥ | ៣,៨៥ | ២,៤២ | (៣,៥៧) |
| អនុបាតសាច់ប្រាក់ងាយស្រួល | ១៤៦,៨៧ | ១៤០,៣៣ | ១៨៥,១០ | ៤៤២,៨២ |
| អនុបាតសាធនភាព | ៤៧,៦៦ | ៣០,០៤ | ៤៨,៣៧ | ៩៦,៨១ |

# លទ្ធផលហិរញ្ញវត្ថុសង្ខេប

### ចំណេញមុនពេលបង់ពន្ធ
(គិតជាពាន់ដុល្លារ អាមេរិក)




### ចំណេញក្រោយពេលបង់ពន្ធ
(គិតជាពាន់ដុល្លារ អាមេរិក)




### ចំណូលសុទ្ធ
(គិតជាពាន់ដុល្លារ អាមេរិក)




### ទ្រព្យសកម្មសរុប
(មាន ១០២ លានដុល្លារ អាមេរិក)




### សមតុល្យឥណទាន និងបុរេប្រទាន
(៤៣ លានដុល្លារ អាមេរិក)
(គិតជាពាន់ដុល្លារ អាមេរិក)




### ប្រាក់បញ្ញើពីអតិថិជន
(គិតជាពាន់ដុល្លារ អាមេរិក)




### ទ្រព្យអកម្ម
### និងមូលនិធិម្ចាស់ហ៊ុន ២០១១




### មូលនិធិម្ចាស់ហ៊ុន
(គិតជាពាន់ដុល្លារ អាមេរិក)



# រចនាសម្ព័ន្ធ (២០១១)




ចំណាំ: អង្គការលេខនេះបង្កើតឡើងនៅឆ្នាំ២០១១

# ក្រុមប្រឹក្សាភិបាល (២០១១)



លោក គីម យ៉ាំងជីន
ប្រធានក្រុមប្រឹក្សាភិបាល ជនជាតិកូរ៉េ



លោក អ៊ីជីរ៉ូ សូ
នាយក ជនជាតិជប៉ុន



លោក ញ៉ាក់ គឹមស្រួយ
នាយក ជនជាតិខ្មែរ

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគទុនិកដើម្បីធ្វើប្រតិបត្តិការ តំណាងឱ្យពួកគេ។ សមាជិកក្រុមប្រឹក្សាភិបាល មានចំនួន ៣ រូប គឺ : លោក គីម យ៉ាំងជីន ជាប្រធានក្រុមប្រឹក្សាភិបាល លោក អ៊ីជីរ៉ូ សូ ជានាយក និង លោក ញ៉ាក់ គឹមស្រួយ ជានាយក។ ក្រុមប្រឹក្សាភិបាលមាននាទីទទួលខុសត្រូវចំពោះការកំណត់យុទ្ធសាស្ត្ររបស់ធនាគារអនុវត្ត និងគ្រប់គ្រងដំណើរការរបស់ធនាគារដែលសមាជិកទាំងអស់ត្រូវអនុវត្តការងារ ដើម្បីឧត្តមប្រយោជន៍របស់ធនាគារ។ ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវចំពោះអភិបាលកិច្ចសាជីវកម្ម និងការជម្រុញភាពជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំ និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការពាណិជ្ជកម្ម និងកិច្ចការរបស់ធនាគារ។ គួរកត់សម្គាល់ថា សមាជិកភាពរបស់ក្រុមប្រឹក្សាភិបាល គឺមិនត្រូវបានកំណត់ត្រឹមសមាជិកនៃគណអភិបាលនោះទេ ប៉ុន្តែក៏មានគណៈគ្រប់គ្រងផងដែរ។

# ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល



**លោក គីម យ៉ាងជីន**
**ប្រធានក្រុមប្រឹក្សាភិបាល ជនជាតិកូរ៉េ**

## កំរិតវប្បធម៌

- អនុបណ្ឌិតវិទ្យាសាស្ត្រអចលនទ្រព្យ ពីសាកលវិទ្យាល័យ Konkuk ក្រុងសេអ៊ូល ប្រទេសកូរ៉េ
- បរិញ្ញាបត្រផ្នែកជីវសាស្ត្រ និងបច្ចេកវិទ្យា ពីសាកលវិទ្យាល័យ Konkuk ក្រុងសេអ៊ូល ប្រទេសកូរ៉េ

## បទពិសោធន៏ការងារ

បទពិសោធន៏ការងាររយៈពេល ៣០ឆ្នាំ ជាមួយធនាគារ គូកមីន, ប្រទេសកូរ៉េ

- នាយករង ធនាគារគូកមីន សាខាក្រុងញូវយ៉ក
- នាយករង នាយកដ្ឋានអាជីវកម្មអន្តរជាតិ
- នាយក នាយកដ្ឋានប្រតិបត្តិការប្តូរប្រាក់
- នាយក នាយកដ្ឋានសាជីវកម្មធនាគារ
- នាយក នាយកដ្ឋានធនាគារខ្នាតតូច និងមធ្យម
- នាយក នាយកដ្ឋានគ្រប់គ្រងឥណទាន
- ប្រធានគ្រប់គ្រងសាជីវកម្មធនាគារ តំបន់និរតី (ការិយាល័យកណ្តាល)
- នាយកប្រតិបត្តិរង ក្រុមហ៊ុន KB Real Estate Trust





**លោក អ៊ីជីរ៉ូ ស៊ូ**
**នាយក ជនជាតិជប៉ុន**

## កំរិតវប្បធម៌

- អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Hitotsubashi ទីក្រុងតូក្យូ ប្រទេសជប៉ុន
- បរិញ្ញាបត្រ ភាសាកូរ៉េ ពីសាកលវិទ្យាល័យ Yonsei ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- បរិញ្ញាបត្រគណនេយ្យ ពីសាកលវិទ្យាល័យ Chuo ប្រទេសជប៉ុន

## បទពិសោធន៍ការងារ

- នាយកប្រតិបត្តិរង SBI Ven Capital Pte., Ltd. ប្រទេសសិង្ហបុរី
- នាយក នាយកដ្ឋានអាជីវកម្មក្រៅប្រទេសនៃ SBI Holdings
- នាយកប្រតិបត្តិរងនៃ Sumitomo Mitsui Banking Corporation សាខាក្រុងសេអ៊ូល ប្រទេសកូរ៉េ



**លោក ញ៉ក់ គឹមស្រួយ**
**នាយក ជនជាតិខ្មែរ**
**(តែងតាំងនៅខែធ្នូ ឆ្នាំ២០១១)**

## កំរិតវប្បធម៌

- អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យ Build Bright ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា
- បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា

## បទពិសោធន៍ការងារ

- ជំនួយការនាយកប្រតិបត្តិនាយកដ្ឋានឥណទាន ធនាគារអេស៊ីលីដា
- ប្រធានផ្នែកវិភាគឥណទាន ធនាគារអេស៊ីលីដា
- នាយកសាខាធនាគារអេស៊ីលីដា

# ព័ត៌មានរួមរបស់ធនាគារ

## ព័ត៌មានសង្ខេបរបស់ធនាគារ

ធនាគារភ្នំពេញពាណិជ្ជ បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដោយទទួលបានអាជ្ញាប័ណ្ណពេញលេញ ជាធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា។ ភាគហ៊ុនរបស់ធនាគារភ្នំពេញពាណិជ្ជ បានមកពីការរួមបញ្ចូលគ្នារវាង Hyundai Swiss Financial Group និងក្រុមហ៊ុនដៃគូដ៏ទៃទៀតដែលមានមូលដ្ឋាននៅប្រទេសកូរ៉េ ចំនួន ៦០ភាគរយ និង SBI Holdings, Inc. ដែលមានមូលដ្ឋាន នៅប្រទេសជប៉ុន ចំនួន ៤០ភាគរយ ។

ក្រុមហ៊ុន Hyundai Swiss Financial Group (HSFG) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧១ គឺជាធនាគារសន្សំប្រាក់ធំជាងគេមួយនៅប្រទេសកូរ៉េផងដែរ។ Hyundai Swiss Saving Bank (HSB)រួមជាមួយនឹង HSB II, HSB III និង HSB IV បច្ចុប្បន្ននេះកំពុងប្រតិបត្តិសាខាជាច្រើននៅទីក្រុងសេអ៊ូល និងនៅតាមបណ្តាខេត្តផ្សេងៗ។

ក្រុមហ៊ុន SBI Group បានផ្តល់ជូននូវតម្លៃផលិតផលទាប និងសេវាដ៏ប្រសើរបំផុតចាប់តាំងពីការធ្វើប្រតិបត្តិរបស់ខ្លួនក្នុងឆ្នាំ ១៩៩៩ មកដោយបានបង្កើនជំនាញអ៊ីនធើណិត និងជំនាញហិរញ្ញវត្ថុយ៉ាងពេញលេញ និងការប្រកាន់យក "គោលការណ៍អតិថិជនជាចំបង"។ តែក្នុងរយៈពេល១០ឆ្នាំ ក្រុមហ៊ុនមានការរីកលូតលាស់យ៉ាងឆាប់រហ័សទៅជាក្រុមហ៊ុនសម្ព័ន្ធហិរញ្ញវត្ថុជាមួយនឹងប្រភេទសេវា និងផលិតផលហិរញ្ញវត្ថុដ៏ពេញលេញរួមមាន ដើមទុនពាណិជ្ជកម្ម បណ្ណភាគហ៊ុនធនាគារ និងក្រុមហ៊ុនធានារ៉ាប់រង។ SBI Group មាន ក្រុមហ៊ុនបុត្រសម្ព័ន្ធជាង៧០ ហើយក្រុមហ៊ុនដែលសំខាន់ជាងគេ គឺ SBI Holdings, Inc., ក្រុមហ៊ុនដែលត្រូវបានចុះបញ្ជីនៅផ្សារភាគហ៊ុន ទីក្រុងតូក្យូ និងមានក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើនទៀតនៅជុំវិញពិភពលោក។

## ព័ត៌មានរួមរបស់ធនាគារ

**ព័ត៌មានរបស់ធនាគារ** (គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១១)

| ឈ្មោះធនាគារ | ធនាគារភ្នំពេញពាណិជ្ជ |
|---|---|
| កាលបរិច្ឆេទបង្កើត | ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ |
| លេខចុះបញ្ជី | Co. ៤៨៩៨E / ២០០៨ |
| អាសយដ្ឋានការិយាល័យកណ្តាល | អគារលេខ ៧៦៧-៧៦៩<br>មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក<br>ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា<br>ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៥០០<br>ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៥៤០ |

| | |
|---|---|
| ដើមទុន | ៣៩ លានដុល្លា អាមេរិក |
| ចំនួនបុគ្គលិក | ៦៧ |

(គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១១)

| | ឈ្មោះ | ចំនួនភាគហ៊ុន | គិតជាភាគរយ |
|---|---|---|---|
| ម្ចាស់ហ៊ុន | SBI Holdings, Inc. | ១៥.៦០០ | ៤០,០០ % |
| | Hidy Investment Co., Ltd | ១៥.៤៣៥ | ៣៩,៥៧ % |
| | Hyundai Swiss I Savings Bank | ១.៤៨៥ | ៣,៨១ % |
| | Hyundai Swiss II Savings Bank | ១.៤៨៥ | ៣,៨១ % |
| | Kyung Ki Growth & Development Co., Ltd | ១.៤៨៥ | ៣,៨១ % |
| | Mr. Kim Kwang Jin | ១.៤៨៥ | ៣,៨១ % |
| | Mr. Kim Jong Min | ១.១២៥ | ២,៨៨ % |
| | Mirae Credit Information Service Corp | ៩០០ | ២,៣១ % |

| | |
|---|---|
| ក្រុមហ៊ុនដៃគូ | SBI Royal Securities |

| | |
|---|---|
| សវនករ | PricewaterhouseCoopers (PWC) |

# បុគ្គលិករបស់ធនាគារភ្នំពេញពាណិជ្ជ

ចំពោះធនាគារភ្នំពេញពាណិជ្ជ ធនធានមនុស្ស គឺជាបេះដូង និងជាព្រលឹងរបស់ធនាគារ និងជាកត្តាដ៏សំខាន់ដែលនាំទៅរកភាពជោគជ័យក្នុងអាជីវកម្ម និងការសម្រេចបាននូវគោលដៅរបស់យើង ។ យើងជឿជាក់យ៉ាងមុតមាំថា ការទទួលបានជោគជ័យ និងការសម្រេចគោលដៅរបស់យើង គឺតម្រូវឱ្យមានធនធានមនុស្សដ៏ខ្លាំងនៅផ្នែកខាងក្នុង ។ ដូចគ្នានេះដែរ ធនាគារភ្នំពេញពាណិជ្ជបន្តថែរក្សា និងអភិវឌ្ឍបុគ្គលិករបស់យើងទាំងសមត្ថភាពផ្នែកផ្លូវកាយ និងផ្លូវចិត្តព្រមទាំងជំនាញវិជ្ជាជីវៈរបស់ពួកគេផងដែរ ។ ទន្ទឹមនឹងនេះដែរយើងក៏បានជ្រើសរើសធនធានមនុស្សដែលមានសមត្ថភាពមកពីខាងក្រៅផងដែរ ។

ធនាគារភ្នំពេញពាណិជ្ជ កំពុងតែបន្តពង្រឹងជំហររបស់ខ្លួន និងបង្កើតបរិយាកាសការងារប្រកួតប្រជែងដើម្បីលើកទឹកចិត្តបុគ្គលិករបស់យើងដែលកំពុងតែបំពេញការងាររបស់ពួកគេបានយ៉ាងល្អ និងជម្រុញពួកគេឱ្យរីកចម្រើនជាមួយយើងផងដែរ ។ ធនាគារភ្នំពេញពាណិជ្ជនឹងផ្តល់រង្វាន់ដល់អ្នកដែលបានបង្ហាញពីការខិតខំបំពេញកិច្ចការងារ និងមានភាពស្មោះត្រង់ក្នុងអាជីវកម្មនិងប្រតិបត្តិការរបស់ធនាគារ និងអ្នកដែលលើកទឹកចិត្តអ្នកផ្សេងទៀតឱ្យរៀនសូត្រតាមរយៈឧទាហរណ៍ និងគំរូល្អៗរបស់ខ្លួន ។












# សមិទ្ធិផលក្នុងឆ្នាំ ២០១១

តាមរយៈការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាពវប្បធម៌ការងារចម្រុះជាតិសាសន៍ និងការលើកទឹកចិត្តបុគ្គលិករបស់យើងឱ្យធ្វើការងារប្រកបដោយភាពប្រកួតប្រជែងគ្នា យើងចង់ឱ្យបុគ្គលិករបស់យើងដឹងថា ពួកគេបានទៅដល់គោលដៅ និងមានអារម្មណ៍ថាមានភាពជិតស្និទ្ធគ្នាជាមួយនឹងការងារពិតប្រាកដរបស់ពួកគេ។ ចលនាផ្លាស់ប្ដូរពីការធ្វើម៉ាឃីធីងបែបប្រពៃណីទៅជាការលក់ទៅកាន់ទីផ្សារដ៏សមស្របមួយតាមរយៈការពិភាក្សាបានធ្វើឱ្យមានការគាំទ្រកាន់តែច្រើន និងទទួលបានតម្លៃកាន់តែខ្ពស់ពីអតិថិជនរបស់យើង។










# គោលដៅយុទ្ធសាស្ត្ររបស់ធនាគារភ្នំពេញពាណិជ្ជ សម្រាប់ឆ្នាំ ២០១១-២០១៤

## មូលដ្ឋានគ្រឹះរឹងមាំ

- ការបំពេញតម្រូវការរបស់អតិថិជន និង
- ការគ្រប់គ្រងត្រឹមត្រូវប្រកបដោយក្រមសីលធម៌

## ការកំណត់ទីតាំង និងការបង្កើនកេរ្តិ៍ឈ្មោះ

- គោលការណ៍ អតិថិជនជាចំបង
- រក្សាឱ្យបាននូវធនធានមនុស្សខាងក្នុងដែលមានជំនាញប៉ិនប្រសប់
- លើកទឹកចិត្តដល់ភាពស្មោះត្រង់របស់បុគ្គលិក
- ធ្វើទីផ្សារ ការផ្សាយពាណិជ្ជកម្ម និង
- បង្កើនបណ្តាញសាខា

## ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធអនុវត្តការងារ

- គ្រប់គ្រងកម្មវិធីសកម្មភាព
- តម្លាភាពនៃការគ្រប់គ្រងធនធានមនុស្ស
- សារៈសំខាន់នៃទំនាក់ទំនង
- បង្ហាញពីចក្ខុវិស័យច្បាស់លាស់
- ធ្វើការសម្រេចចិត្តបានយ៉ាងរហ័ស

២០១១

# ២០១៤

## ជាធនាគារឈានមុខមួយក្នុងចំណោមប្រាំ

ក្លាយជាធនាគារមួយក្នុងចំណោមធនាគារឈានមុខគេទាំងប្រាំនៅកម្ពុជា

## ទទួលបានអត្រាកំណើនប្រចាំឆ្នាំទ្វេដង

ទទួលបានអត្រាកំណើនប្រចាំឆ្នាំទ្វេដងនៃអត្រាកំណើនមធ្យមរបស់វិស័យធនាគារនៅកម្ពុជា

# ផលិតផល និងសេវា

ធនាគារភ្នំពេញពាណិជ្ជ ផ្តល់ជូនគ្រប់ប្រភេទសេវា និងផលិតផលទាំងអស់របស់ធនាគារពាណិជ្ជ រួមមាន គណនីចរន្ត គណនីសំចៃ គណនីសន្សំមានកាលកំណត់ គណនីសន្សំថេរ ឥណទានអាជីវកម្ម ឥណទានគេហដ្ឋាន ឥណទានផ្ទាល់ខ្លួន (ឥណទានរៀបអាពាហ៍ពិពាហ៍) ឥណទានរថយន្ត ឥណទានម៉ូតូ ការផ្ទេរប្រាក់ និងសេវាហិរញ្ញប្បទានពាណិជ្ជកម្មផងដែរ។

សាខាទាំងអស់របស់ធនាគារភ្នំពេញពាណិជ្ជ បំពាក់ដោយម៉ាស៊ីន ATM ២៤/៧ និងម៉ាស៊ីន ATM នៅទីកន្លែងផ្សេងៗ ជាច្រើនទៀតដើម្បីផ្តល់សេវាពេញលេញដល់អតិថិជនរបស់យើង។

## ឥណទាន

- ឯកត្តជន
- សាជីវកម្ម
- ឥណទានបញ្ចាំ

## ប្រាក់បញ្ញើ

- គណនីចរន្ត
- គណនីសន្សំ
- ប្រាក់បញ្ញើមានកាលកំណត់
- ប្រាក់បញ្ញើផ្សេងៗ

## ពាណិជ្ជកម្មអាស្រ័យកម្រៃ

- សេវាផ្ទេរប្រាក់ក្នុងប្រទេស និងជាអន្តរជាតិ
- លិខិតឥណទាន
- ការពិគ្រោះយោបល់ (អចលនទ្រព្យ IPO)
- ការចេញសញ្ញាប័ណ្ណ

## ធនាគារសាជីវកម្ម

- ការអោយខ្ចីជារូបិយប័ណ្ណបរទេស
- លិខិតឥណទាន និងការធានា

## ពាណិជ្ជកម្មអន្តរជាតិ

- ហិរញ្ញប្បទានគម្រោង
- ហិរញ្ញប្បទាន និងការបែងចែកភាគលាភ
- ការវិនិយោគផ្ទាល់



# ធនាគារ ភ្នំពេញ ពាណិជ្ជ
# Phnom Penh Commercial Bank




ចង់ទិញម៉ូតូថ្មីមែនទេ?
ធនាគារ ភ្នំពេញ ពាណិជ្ជ
ធ្វើអោយបំណងរបស់លោកអ្នកសំរេចបាន!
ជាមួយនឹង ឥណទានម៉ូតូ
លោកអ្នកនឹងមានម៉ូតូថ្មីដូចខ្ញុំដែរ!
ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
SBI Phnom Penh securities


ឥណទានម៉ូតូ
ធនាគារ ភ្នំពេញ ពាណិជ្ជ តែងតែនៅជាមួយលោកអ្នក ពេលដែលលោកអ្នកត្រូវការម៉ូតូថ្មី ១គ្រឿង
លោកអ្នកនឹងទទួលបាននូវសេវាកម្មរហ័សទាន់ចិត្ត
លោកអ្នកមានត្រឹមតែ ៣០ភាគរយ ប៉ុណ្ណោះ លោកអ្នកអាចទទួលបានម៉ូតូថ្មី ១គ្រឿង ដូចបំណង
ទំហំឥណទាន : ៧០ភាគរយនៃតំលៃម៉ូតូ
រយៈពេល : រហូតដល់ ៣៦ ខែ
អត្រាការប្រាក់ : ១៩ភាគរយ ក្នុង១ឆ្នាំ
របៀបសងប្រាក់: សងរំលស់ទាំងដើមទាំងការរៀងរាល់ខែ
ព័ត៌មានបន្ថែមសូមទំនាក់ទំនង:
ទីស្នាក់ការកណ្ដាល
៧៦៧-៧៦៩ មហាវិថីព្រះមុនីវង្ស
សង្កាត់បឹងត្របែក ខណ្ឌចំការមន
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០២៣ ៩៩៩ ៥២៤
លោក ចេង សុខ មន្ត្រីឥណទាន
០១៧ ៣៧៧ ៧៣១
ទូរសារ: ០២៣ ៩៩៩ ៥៤០
សាខាប៊ីអេស
អគារប៊ីអេស មហាវិថីព្រះមុនីវង្ស
សង្កាត់មនោរម្យ ខណ្ឌ៧មករា
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០២៣ ៩៩៩ ៦០០
លោក អ៊ីង ឫទ្ធិភ័ណ្ឌសាក់ មន្ត្រីឥណទាន
០១៥ ៣០៣ ៦១៦
ទូរសារ: ០២៣ ៩៩៩ ៤០០
សាខាផ្សារដើមគ
អគារលេខ: ៧៨ មហាវិថីព្រះមុនីរ៉េត
សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន
ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០២៣ ៩៩៩ ៧០០
លោក យឹម សុធន់ មន្ត្រីឥណទាន
០៧៧ ៧០៤ ៨៧៦
ទូរសារ: ០២៣ ៩៩៩ ៧០១


ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
ជាមួយឥណទានរថយន្ត :
លោកអ្នកនឹងទទួលបានរថយន្ត ១គ្រឿង ដោយគ្រាន់តែមានប្រាក់ ៥០%ប៉ុណ្ណោះ
ការបង់រំលោះរយៈពេល : ៤ឆ្នាំ
អត្រាការប្រាក់ : ១៤%ក្នុង ១ឆ្នាំ
ទំហំឥណទាន : ៥០% នៃតម្លៃរថយន្ត


ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
លោកអ្នកអាចទទួលបានរថយន្តថ្មី ជាមួយនឹង
អត្រាការប្រាក់សមរម្យ និងបង់រំលោះរយៈពេលវែង


ជាមួយនឹងឥណទានគេហដ្ឋាន លោកអ្នកនឹង:
ទទួលបាននូវគេហដ្ឋានថ្មីដូចបំណង
ទទួលបានប្រាក់កម្ចីរហូតដល់ ៦០% នៃតម្លៃផ្ទះ
ទទួលបាននូវអត្រាការប្រាក់សមរម្យ
បង់រំលស់រយៈពេល ១០ឆ្នាំ
សម្រាប់ព័ត៌មានបន្ថែមសូមអញ្ជើញមកទំនាក់ទំនងគ្រប់សាខាធនាគារ ភ្នំពេញ ពាណិជ្ជ :
ទីស្នាក់ការកណ្ដាល
សាខាប៊ីអេស
សាខាផ្សារដើមគ
សាខាទួលគោក
សាខាសៀមរាប


ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
ឥណទានគេហដ្ឋាន
លោកអ្នកនឹងទទួលបាននូវ
គេហដ្ឋានថ្មីមួយដូចក្ដីស្រម៉ៃ !
សេវារហ័សទាន់ចិត្ត !...


Tuol Kork Branch
#24, st 273, Tuol Kork, Phnom Penh
Tel: (855) 23 999 050
Fax: (855) 23 999 151
Siem Reap Branch
Tel: (855) 63 967 500
Fax: (855) 63 967 600


ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
Customer is a flower
Your beautiful life with PPCB
* Our new financial partner:
SBI Phnom Penh securities
Head Office
767-769, Preah Monivong Blvd, Beoung Trabek Quarter, Chamkarmorn District, Phnom Penh, Cambodia.
Tel: (855) 23 999 500
Fax: (855) 23 999 540
Fixed Deposit Account
2.50% 3.00% 4.20% 5.20% 6.20%
1 month 2 months 3 months 6 months 12 months
* New Fixed Deposit (Credit Interest Monthly to S/A or C/A)
Fixed Deposit-Monthly Interest Payment
Terms | Rates
3 Months 3.50% p.a
6 Months 4.70% p.a
12 Months 5.70% p.a
In case of break term, customer must be return back all interest paid plus taxation, saving interest rate will be provided.
Installment Deposit
Installment Deposit Account
Installment Deposit Account (Minimum opening balance: USD10)
6 Months 3.00% p.a
12 Months 4.00% p.a
24 Months 5.50% p.a
36 Months 6.50% p.a
Premier Installment Deposit Account (Minimum Opening balance: USD500)
6 Months 4.00% p.a
12 Months 5.00% p.a
24 Months 6.00% p.a
36 Months 6.75% p.a
Saving Account
Terms | Rates
1 year | 1.20% p.a.
BS Branch
BS Department Store, Monivong Blvd., Monorom Quarter, 7 Makara District, Phnom Penh, Cambodia.
Tel: (855) 23 999 600
Fax: (855) 23 999 400
Loan & Advance
PPCB is a reliable source of providing various types of credit services to support you, your family and your business. We are certain that with the designed credit services at PPCB, you can make a better choice for your day-to-day source of fund.
Currently, PPCB provide Loan and Trade service below:
Loan Service
Motor Loan (Small Business Loan)
Green Loan (Small Business Loan)
Medium Business Loan
Large Loan
Personal Loan
Overdraft
Revolving Loan
Housing Loan
Trade Finance
Documentary Credit (L/C)
Bank Guarantee
Phsar Deum Kor Branch
#78, Monireth Blvd., Toul Svay Prey II,Chamkarmorn, Phnom Penh, Cambodia.
Tel: 023 999 700
Fax: 023 999 701


ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
ឥណទានគេហដ្ឋាន


ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
Opening Soon!
TK Branch #24, st 273, Phnom Penh
DEPOSIT
Term Deposit
Saving Deposit
LOAN
Loan Service
Trade Finance
ATM
FUNCTION
ATM LOCATIONS
ATM Service: 24/7
Free ATM Card, ATM Transaction


ហ្គ្រីនឡូន
សេវាកម្មឥណទានខ្នាតតូច
ហ្គ្រីនឡូន GREEN LOAN
ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
SBI Phnom Penh securities

# សេចក្តីផ្តើមរបស់ Hyundai Swiss Financial Group (HSFG)

ក្រុមហ៊ុន ហ៊ីយ៉ាន់ដាយស្វីស (Hyundai Swiss Financial Group) បានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុនាំមុខគេ ដែលរួមមាន ធនាគារ HSB ធនាគារ HSB II ធនាគារ HSB III ក្រុមហ៊ុន Hyundai Swiss Asset Management និងធនាគារភ្នំពេញពាណិជ្ជ (PPCB) នៅកម្ពុជា។ Hyundai Swiss Savings Bank (HSB) ដែលជាបណ្តាញរបស់ HSFG គឺជាធនាគារសន្សំប្រាក់ដំបូងរបស់កូរ៉េដែលទាក់ទាញការវិនិយោគបរទេសពី Merce International របស់ប្រទេសស្វីស ដែលត្រូវបានចុះក្នុងបញ្ជី NASDAQ ក្នុងខែកក្កដា ឆ្នាំ២០០០ និងសាជីវកម្ម SoftBank Corporation របស់ប្រទេសជប៉ុន ក្នុងខែឧសភា ឆ្នាំ២០០២។ ដូចនេះ HSFG បានបង្ហាញពីការគ្រប់គ្រងប្រកបដោយភាពត្រឹមត្រូវ និងសក្តានុពលនៃការលូតលាស់របស់ខ្លួន។

ដោយការរៀបចំខ្លួនយ៉ាងយកចិត្តទុកដាក់ដើម្បីឈានចូលទៅកាន់ទីផ្សារអន្តរជាតិ ដូចជា ប្រទេសកម្ពុជា និងប្រទេសវៀតណាម HSFG បានបង្កើតនាយកដ្ឋានផ្នែកពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួនក្នុងឆ្នាំ២០០៧ ព្រមទាំងបានជម្រុញការវិនិយោគលើវិស័យអចលនទ្រព្យ និងទីផ្សារមូលធននៃទីផ្សារអន្តរជាតិថ្មីៗទៀតផង។ ជាលទ្ធផល HSFG បានទទួលជោគជ័យក្នុងការបង្កើតធនាគារភ្នំពេញពាណិជ្ជ (PPCB) ក្នុងប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៨ ដែលធនាគារភ្នំពេញពាណិជ្ជ (PPCB) អាចរក្សាបាននូវធនធានបរទេស និងទ្រព្យសម្បត្តិដែលមានគុណភាពខ្ពស់។

វិទ្យាសាស្ត្ររកប្រាក់ គំរូការផ្ទេរដែលមានឥទ្ធិពលគ្របដណ្តប់លើទ្រឹស្តីហិរញ្ញវត្ថុបែបប្រពៃណី គឺជាចំណេះដឹងនៃមូលដ្ឋានហិរញ្ញវត្ថុ ដែលស្ថិតនៅពីក្រោយធនាគារ Hyundai Swiss Financial Group។ ចាប់ពីគំរូប្រព័ន្ធធនាគាររហូតដល់គំរូប្រាក់ចំណូលផ្សេងៗនៃការគ្រប់គ្រងទ្រព្យសកម្ម ក្រុមហ៊ុនបុត្រសម្ព័ន្ធ Hyundai Swiss Financial Group ពង្រីកទ្រព្យសម្បត្តិអតិថិជនរបស់ពួកគេជាមួយនឹងស្ថិរភាព និងប្រសិទ្ធភាពដោយឈរលើមូលដ្ឋាន "វិទ្យាសាស្ត្ររកប្រាក់"។



# បណ្តាញ HSB

ពីធនាគារពាណិជ្ជទៅជាការគ្រប់គ្រងទ្រព្យសកម្ម
គ្រប់ប្រព័ន្ធធនាគារទាំងអស់ចាប់ផ្តើមជាមួយនឹងវិទ្យាសាស្ត្ររកប្រាក់។

### ធនាគារ ហ៊ីយ៉ាន់ដាយស្វីស (HSB) SAVING BANK

**ធនាគារដែលតែងតែនៅជាមួយអ្នក**

ធនាគារ ហ៊ីយ៉ាន់ដាយស្វីស (HSB) បន្តរីកលូតលាស់ក្នុងបរិយាកាសហិរញ្ញវត្ថុដែលមានបម្រែបម្រួលយ៉ាងឆាប់រហ័ស។

>



### ក្រុមហ៊ុន HYUNDAI SWISS ASSET MANAGEMENT

**ដោយនាំឆ្ពោះទៅរកគំរូហិរញ្ញវត្ថុថ្មីមួយ**

យើងនឹងទាញយកប្រយោជន៍ពីធនធានមនុស្សដែលមានជំនាញប៉ិនប្រសប់ និងប្រព័ន្ធវិនិយោគផ្នែកវិទ្យាសាស្ត្រដ៏ប្រសើរមួយ។

>



### ក្រុមហ៊ុន HYUNDAI SWISS II SAVING BANK

**ជាដៃគូហិរញ្ញវត្ថុដែលអាចទុកចិត្តបានមួយ**

តាមរយៈការព្យាករយ៉ាងសកម្មអំពីការផ្លាស់ប្តូរ និងការអនុវត្តប្រព័ន្ធវិនិយោគជឿនលឿនមួយ យើងនឹងយកចិត្តទុកដាក់ចំពោះអតិថិជនរបស់យើងជានិច្ច។

>



### ធនាគារ ភ្នំពេញពាណិជ្ជ (PPCB)

**ធនាគារបរទេសដែលល្អបំផុត**

ធនាគារ ហ៊ីយ៉ាន់ដាយស្វីស (HSB) បានបោះជំហានជាអ្នកឈានមុខផ្នែកហិរញ្ញវត្ថុ ពេលនេះក្លាយជាធនាគារហិរញ្ញវត្ថុសកល។

>



# សេចក្តីផ្តើមរបស់ SBI Holdings, Inc.

## ព័ត៌មានសង្ខេបរបស់ក្រុមហ៊ុន

(គិតត្រឹមថ្ងៃទី ១ ខែតុលា ឆ្នាំ២០១១)

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | SBI Holdings, Inc. |
| ទីស្នាក់ការកណ្តាល | 19F Izumi Garden Tower 1-6-1, Roppongi, Minato-ku, Tokyo 106-6019 Japan |
| ទីសដៅអាជីវកម្ម | Control and management of SBI Group through share ownership |
| ថ្ងៃបង្កើតក្រុមហ៊ុន | ថ្ងៃទី ៨ ខែកក្កដា ឆ្នាំ១៩៩៩ |
| ដើមទុន | ៨១.៦៦៣ លានយេន |
| ចំនួនភាគហ៊ុន | ២២.៣៧៦.២៣៤ |
| ចំនួនបុគ្គលិក | ៣.២៦៧ |

## បេសកម្មរបស់ក្រុមហ៊ុន SBI Group និងទស្សនៈពីការកសាងមូលដ្ឋានពាណិជ្ជកម្ម

### ទស្សនៈនៃការគ្រប់គ្រងរបស់ SBI Group

**○ គុណតម្លៃប្រកបដោយសីលធម៌ :**

យើងត្រូវទទួលខុសត្រូវលើការវិនិច្ឆ័យលើសកម្មភាព ដោយមិនត្រូវពឹងផ្អែកតែលើថាតើវាស្របតាមច្បាប់ ឬផ្តល់ផលចំណេញដល់ក្រុមហ៊ុននោះទេ ប៉ុន្តែ ក៏ត្រូវមើលថាតើមានសមធម៌នៅក្នុងសង្គមផងដែរ ។

**○ អ្នកផ្លាស់ប្តូរផ្នែកហិរញ្ញវត្ថុ :**

យើងនឹងផ្លាស់ប្តូរវិធីសាស្ត្របែបប្រពៃណី ហើយនាំយកការបង្កើតថ្មីផ្នែកហិរញ្ញវត្ថុទៅកាន់ភាព ឈានមុខនៃឧស្សាហកម្មហិរញ្ញវត្ថុ ប្រើប្រាស់ឱកាសមកពីការបញ្ចុះតម្លៃអ៊ីនធើណិត និងអភិវឌ្ឍសេវាហិរញ្ញវត្ថុដែលបង្កើនផលប្រយោជន៍បន្ថែមសម្រាប់អតិថិជន ។

**○ អ្នកបង្កើតឧស្សាហកម្មថ្មី :**

យើងនឹងធ្វើការដើម្បីក្លាយជាអ្នកដឹកនាំក្នុងការបង្កើត និងទទួលផលពីឧស្សាហកម្មស្នូលនាសតវត្សរ៍ទី ២១ ។

**○ ការវិវត្តដោយខ្លួនឯង :**

យើងនឹងបន្តដើម្បីក្លាយខ្លួនជាក្រុមហ៊ុន ដែលវិវត្តដោយឆន្ទៈផ្ទាល់ខ្លួន តាមរយៈការបង្កើតជាក្រុមហ៊ុនដែលអាចបត់បែនសម្របទៅតាមការប្រែប្រួលក្នុងបរិយាកាស ប្រតិបត្តិការព្រមទាំងបង្កើត"ភាពប៉ិនប្រសប់" និង"ការផ្លាស់ប្តូរខ្លួនឯង"ជាផ្នែកDNA របស់ក្រុមហ៊ុន ។

**○ ការទទួលខុសត្រូវក្នុងសង្គម :**

យើងនឹងធានាថា ក្រុមហ៊ុននីមួយៗ របស់ SBI Group ទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនក្នុងសង្គមក្នុងឋានៈជាសមាជិកមួយរបស់សង្គម ខណៈពេលបំពេញតម្រូវការរបស់ម្ចាស់ភាគហ៊ុននិងត្រូវចូលរួមធ្វើឱ្យសង្គមកាន់តែប្រសើរឡើង ។

## ទស្សនៈជាមូលដ្ឋានក្នុងការកសាងពាណិជ្ជកម្មរបស់ SBI Group

### ① ការអនុវត្តតាម "គោលការណ៍ផ្តោតជាសំខាន់លើអតិថិជន"

យើងនឹងបន្តបង្កើននូវប្រយោជន៍របស់អតិថិជន ក៏ដូចជាពង្រីកផលប្រយោជន៍របស់ក្រុមហ៊ុនជាអតិបរមា តាមរយៈការប្រើប្រាស់ការប្រមូលផ្តុំរវាងផលប្រយោជន៍របស់អតិថិជន ផលប្រយោជន៍ម្ចាស់ភាគហ៊ុន និងផលប្រយោជន៍ធនធានមនុស្ស ដែលតែងតែអនុវត្តតាមគោលការណ៍ផ្តោតជាសំខាន់លើអតិថិជនរបស់យើង ។

### ② ការបែងចែកភាពខុសគ្នានៃរចនាសម្ព័ន្ធ

យើងបែងចែកភាពខុសគ្នារបស់យើងពីអ្នកប្រកួតប្រជែងតាមរយៈភាពខុសគ្នានៃរចនាសម្ព័ន្ធដែលត្រូវបានបង្កើតក្នុងក្រុមហ៊ុនរបស់យើង ដូចជាតាមរយៈ ផលិតផល និងសេវាចម្រុះរបស់យើង ។ វិធីសាស្ត្រដែលបង្កើតរចនាសម្ព័ន្ធនេះ អនុញ្ញាតឱ្យយើងទទួលជោគជ័យក្នុងការប្រកួតប្រជែង និង រក្សាសក្តានុពលនៃការរីកចម្រើនរបស់យើង ។

### ③ ការបង្កើតបណ្តាញផលប្រយោជន៍

យើងនឹងបន្តដើម្បីស្វែងរកការពង្រីកបណ្តាញ និងការរីកចម្រើននៃក្រុមហ៊ុនរបស់យើងក្នុង "ប្រព័ន្ធអេកូពាណិជ្ជកម្ម" នៃវិស័យពាណិជ្ជកម្មនានា ជាជាងការប្រមូលផ្តុំពាណិជ្ជកម្មដាច់ដោយឡែកមួយដែលមិនទាក់ទង គ្នាដែលត្រូវបានបែងចែកដោយផ្នែក ។

ធនាគារ ភ្នំពេញ ពាណិជ្ជ

Phnom Penh Commercial Bank

# របាយការណ៍ហិរញ្ញវត្ថុ
# របាយការណ៍របស់សវនករឯករាជ្យ (២០១១)



# ធនាគារ ភ្នំពេញ ពាណិជ្ជ

## របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

# ធនាគារ ភ្នំពេញ ពាណិជ្ជ

## របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ២៥- ២ ៩ |
| របាយការណ៍សវនករឯករាជ្យ | ៣០-៣១ |
| របាយការណ៍ហិរញ្ញវត្ថុ | |
| របាយការណ៍លទ្ធផល | ៣២ |
| តារាងតុល្យការ | ៣៣ |
| របាយការណ៍បម្រែបម្រួលមូលធន | ៣៤ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៣៥ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ៣៦-៨៧ |
| ឧបសម្ព័ន្ធ : កំណត់សម្គាល់ចំពោះការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាល* | ៨៨-១០២ |


* ឧបសម្ព័ន្ធនេះ មិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនេះទេ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារ ភ្នំពេញ ពាណិជ្ជ (ហៅកាត់ថា "ធនាគារ") សូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារដែលបានធ្វើសវនកម្មរួចហើយ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។

## សកម្មភាពចម្បងៗ

សកម្មភាពចម្បងៗរបស់ធនាគារ គឺការផ្តល់សេវាកម្មផ្នែកធនាគារជាច្រើនប្រភេទ និងសេវាកម្មផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

## លទ្ធផលប្រតិបត្តិការ និងភាគលាភ

លទ្ធផលប្រតិបត្តិការ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបង្ហាញជូនក្នុងរបាយការណ៍លទ្ធផល ទំព័រទី ៨។

មិនមានការប្រកាស ឬការបង់ភាគលាភក្នុងឆ្នាំទេ (២០១០ : គ្មាន)។

## ដើមទុនចុះបញ្ជី

ដើមទុនចុះបញ្ជីរបស់ធនាគារ ត្រូវបានបង្កើនពី ១៥.000.000 ដុល្លារអាមេរិក ទៅ ៣៩.000.000 ដុល្លារអាមេរិក នៅក្នុងឆ្នាំ។

## ឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះ និងធ្វើសំវិធានធន ឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យ ចេញពីបញ្ជី និងបានយល់ស្របថា ការជម្រះ និងសំវិធានធនគ្រប់គ្រាន់ ត្រូវបានធ្វើចំពោះឥណទាន និង បុរេប្រទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយនៃឥណទាន និងបុរេប្រទានអតិថិជនអាក្រក់ ឬចំនួនសំវិធានធនសម្រាប់ឥណទាន និងបុរេប្រទានអតិថិជន អាក្រក់ និងសង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលមានលក្ខណៈមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា តាមតម្លៃក្នុងបញ្ជីរបស់ធនាគារ ត្រូវបានកាត់បន្ថយឱ្យស្មើនឹងតម្លៃ ដែលរំពឹងថានឹងអាចលក់បាននៅលើទីផ្សារជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលបណ្តាលឱ្យតម្លៃនៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមិនត្រឹមត្រូវនោះឡើយ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ការិយបរិច្ឆេទហិរញ្ញវត្ថុមក ឬ

ខ. ទ្រព្យអកម្មយថាភាពណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅពីទ្រព្យអកម្មនៅក្នុងដំណើរការអាជីវកម្មធនាគារធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល មិនមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗរបស់ធនាគារ ដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសង ក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃផុតកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានកំហុសឆ្គងនោះឡើយ។

## គណនីដែលមានលក្ខណៈមិនធម្មតា

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានរងនូវការប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតានោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្នុងចន្លោះរវាងដំណាច់ការិយបរិច្ឆេទហិរញ្ញវត្ថុ មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតា ដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រងប្រតិបត្តិ ដែលបានបម្រើការក្នុងអំឡុងឆ្នាំ និងរហូតមកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

ក្រុមប្រឹក្សាភិបាល ៖

- លោក Kim Yang Jin — ប្រធាន
- លោក Eiichiro So — នាយក
- លោក Nhak Kimsroy — នាយក (បានតែងតាំងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមប្រឹក្សាភិបាល)

គណៈគ្រប់គ្រងប្រតិបត្តិ ៖

- លោក Kim Yang Jin — អគ្គនាយក និង នាយកប្រតិបត្តិ
- លោក Kim Bok Rae — នាយករង
- លោក Nhak Kimsroy — នាយក
- លោក Ryu Jae kyung — នាយក
- លោក Samnom Saruth — ប្រធានសវនកម្មផ្ទៃក្នុង
- លោក Yun Chang Ho — ប្រធានផ្នែកយុទ្ធសាស្ត្រ និងផែនការ
- លោក Sen Chettana — ប្រធានគណនេយ្យ

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងឆ្នាំ និងគិតត្រឹមដំណាច់ឆ្នាំនេះ ពុំមានការព្រមព្រៀងណាមួយដែលធនាគារបានចូលរួមជាភាគី ក្នុងគោលបំណងជួយសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ ឱ្យទទួលបាននូវផលប្រយោជន៍ តាមរយៈការទិញយកភាគហ៊ុន ឬលិខិតបំណុលពីសាម៉ីធនាគារ ឬក្រុមហ៊ុនដទៃទៀតទេ ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារណាម្នាក់ ទទួលបាន ឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយធនាគារ ឬកិច្ចសន្យារវាងធនាគារ និងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលរូបនោះជាសមាជិក ឬក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលរូបនោះ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្ត ក្រៅពីបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះឡើយ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល ចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបង្ហាញយ៉ាងត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ តម្រូវឱ្យក្រុមប្រឹក្សាភិបាល :

១. ប្រើប្រាស់គោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន បន្ទាប់ពីនោះត្រូវអនុវត្តគោលការណ៍ទាំងនោះឱ្យបានស៊ីសង្វាក់គ្នា។

២. អនុវត្តតាមគោលការណ៍ណែនាំ ដែលចេញដោយធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះ ត្រូវបានបង្ហាញពន្យល់ និងកំណត់បរិមាណយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃអាជីវកម្ម លើកលែងតែមានករណីសមរម្យក្នុងការសន្មតថា ធនាគារនឹងមិនអាចបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. ត្រួតពិនិត្យ និងដឹកនាំធនាគារ ដោយចូលរួមលើរាល់ការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំជាក្រុមប្រឹក្សាភិបាល បានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ រួមនឹងកំណត់សម្គាល់ផ្សេងៗ ដែលបានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ក៏ដូចជាលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ចុះហត្ថលេខាស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

លោក Kim Yang Jin

អគ្គនាយក និង នាយកប្រតិបត្តិ

កាលបរិច្ឆេទ : ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២

# របាយការណ៍សវនករឯករាជ

## ជូនភាគទុនិកធនាគារ ភ្នំពេញ ពាណិជ្ជ

យើងខ្ញុំបានធ្វើសវនកម្ម ទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ របស់ធនាគារ ភ្នំពេញ ពាណិជ្ជ (ហៅកាត់ថា "ធនាគារ") រួមមានតារាងតុល្យការគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និងសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងៗទៀត ។

### *ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ*

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំផ្សេងៗ ចេញដោយធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

### *ការទទួលខុសត្រូវរបស់សវនករ*

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ស្តង់ដារទាំងនោះ តម្រូវឱ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើសវនកម្មដើម្បីទទួលបានការធានាអះអាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្ម រួមមានការអនុវត្តនីតិវិធីដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការលាតត្រដាងបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ រាប់ទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារនោះទេ។ សវនកម្ម ក៏រាប់ទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ដែលគណៈគ្រប់គ្រងបានធ្វើឡើង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជូនជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### *មតិយោបល់*

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និង ស្តង់ដារគណនេយ្យកម្ពុជា។

ជ. PricewaterhouseCoopers (Cambodia) Ltd.

គុយ លីម
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ : ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# របាយការណ៍លទ្ធផល
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | កំណត់សម្គាល់ | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | ៤ | ៤.៥៦០.៨៦៨ | ២.៩៩២.៨០១ | ១៨.៤២១.៣៤៥ | ១២.១២៩.៨២២ |
| ចំណាយការប្រាក់ | ៥ | (១.៣២៥.៦៨៥) | (១.០៧៤.៦៦៦) | (៥.៣៥៤.៤៤២) | (៤.៣៥៥.៦២១) |
| ចំណូលការប្រាក់សុទ្ធ | | ៣.២៣៥.១៨៣ | ១.៩១៨.១៣៥ | ១៣.០៦៦.៩០៣ | ៧.៧៧៤.២០១ |
| ចំណូលកម្រៃ និងជើងសារ | ៦ | ៩៣៩.៤៨៦ | ៦២២.៤៤០ | ៣.៧៩៤.៥៨៤ | ២.៥២២.៧៤៩ |
| ចំណាយទូទៅ និងរដ្ឋបាល | ៧ | (២.៣១១.៩៩១) | (១.៧០១.៩០៦) | (៩.៣៣៨.១៣៣) | (៦.៨៩៧.៨២៦) |
| សំវិធានធនសម្រាប់ឥណទាន និង បុរេប្រទានអតិថិជន អាក្រក់ និង សង្ស័យ | ១១ (ក) | (១៨៥.៤៨៣) | (១១០.៤៩៥) | (៧៤៩.១៦៦) | (៤៤៧.៨៣៦) |
| ចំណេញមុនបង់ពន្ធ | | ១.៦៧៧.១៩៥ | ៧២៨.១៧៤ | ៦.៧៧៤.១៨៨ | ២.៩៥១.២៨៨ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៨ | (៣៦៤.៤២៩) | (១៣៣.៩៩៤) | (១.៤៧១.៩២៩) | (៥៤៣.០៧៨) |
| **ចំណេញសុទ្ធក្នុងឆ្នាំ** | | **១.៣១២.៧៦៦** | **៥៩៤.១៨០** | **៥.៣០២.២៥៩** | **២.៤០៨.២១០** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ចាប់ពីទំព័រទី ១២ ដល់ ៦៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
## តារាងតុល្យការ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | កំណត់សម្គាល់ | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ៤.២៥៧.២២៨ | ២.២៣៥.៨៣៦ | ១៧.១៩៤.៩៤៤ | ៩.០៦១.៨៤៣ |
| សមតុល្យនៅធនាគារកណ្តាល | ៩ | ១១.៦៤៥.៧៦៩ | ៥.៣៦៤.២៣៧ | ៤៧.០៣៧.២៦១ | ២១.៧៤១.២៥៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១០ | ៤០.៨៥៣.៥៣៥ | ២៤.៨៣៥.៥៨៨ | ១៦៥.០០៧.៤២៨ | ១០០.៦៥៨.៦៣៩ |
| ឥណទាន និងបុរេប្រទានអតិថិជន | ១១ | ៤២.៨៦២.១៨១ | ២៤.៤៩៩.៤៩៥ | ១៧៣.១២០.៣៥០ | ៩៩.២៩៦.៤៥៤ |
| ទ្រព្យសកម្មផ្សេងៗ | ១២ | ១.៣៥៦.១១០ | ៦២៥.៦២៩ | ៥.៤៧៧.៣២៨ | ២.៥៣៥.៦៧៤ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១៣ | ៨៤៤.២៩០ | ៥៤៦.៤១៤ | ៣.៤១០.០៨៧ | ២.២១៤.៦១៧ |
| ទ្រព្យសកម្មអរូបី | ១៤ | ២៣២.៣០៨ | ២៤៣.៥៩៤ | ៩៣៨.២៩៣ | ៩៨៧.២៨៦ |
| **ទ្រព្យសកម្មសរុប** | | **១០២.០៥១.៤២១** | **៥៨.៣៥០.៧៩៣** | **៤១២.១៨៥.៦៩១** | **២៣៦.៤៩៥.៧៦៦** |
| **ទ្រព្យអកម្ម និងមូលធនភាគទុនិក** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១៥ | ៣០.៦៣៨.០០២ | ២២.៦៩០.៣២២ | ១២៣.៧៤៦.៨៩០ | ៩១.៩៦៣.៨៧៥ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៦ | ២៩.៦៨៨.២៦៦ | ១៩.៤៦៣.៩៨៤ | ១១៩.៩១០.៩០៧ | ៧៨.៨៨៧.៥២៧ |
| បង្ករ និងទ្រព្យអកម្មផ្សេងៗ | ១៧ | ៦៦៣.៧៣០ | ៦៥៨.៣៧៤ | ២.៦៨០.៨០៧ | ២.៦៦៨.៣៩២ |
| បំណុលពន្ធលើប្រាក់ចំណេញ | ៨ (ខ) | ៣១១.៩៩២ | ១០១.៤៤៨ | ១.២៦០.១៣៥ | ៤១១.១៦៩ |
| **ទ្រព្យអកម្មសរុប** | | **៦១.៣០១.៩៩០** | **៤២.៩១៤.១២៨** | **២៤៧.៥៩៨.៧៣៩** | **១៧៣.៩៣០.៩៦៣** |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | ១៨ | ៣៩.០០០.០០០ | ១៥.០០០.០០០ | ១៥៧.៥២១.០០០ | ៦០.៧៩៥.០០០ |
| ចំណេញរក្សាទុក | | ១.៧៤៩.៤៣១ | ៤៣៦.៦៦៥ | ៧.០៦៥.៩៥២ | ១.៧៦៩.៨០៣ |
| **មូលធនភាគទុនិកសរុប** | | **៤០.៧៤៩.៤៣១** | **១៥.៤៣៦.៦៦៥** | **១៦៤.៥៨៦.៩៥២** | **៦២.៥៦៤.៨០៣** |
| **ទ្រព្យអកម្ម និងមូលធនភាគទុនិកសរុប** | | **១០២.០៥១.៤២១** | **៥៨.៣៥០.៧៩៣** | **៤១២.១៨៥.៦៩១** | **២៣៦.៤៩៥.៧៦៦** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ចាប់ពីទំព័រទី ១២ ដល់ ៦៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# របាយការណ៍បម្រែបម្រួលមូលធន
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | ដើមទុន<br>ដុល្លារអាមេរិក | ចំណេញរក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ | ១៥.០០០.០០០ | (១៥៧.៥១៥) | ១៤.៨៤២.៤៨៥ |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | ៥៩៤.១៨០ | ៥៩៤.១៨០ |
| **សមតុល្យគិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | **១៥.០០០.០០០** | **៤៣៦.៦៦៥** | **១៥.៤៣៦.៦៦៥** |
| សមមូលជាពាន់រៀល *(មិនបានធ្វើសវនកម្ម)* | **៦០.៧៩៥.០០០** | **១.៧៦៩.៨០៣** | **៦២.៥៦៤.៨០៣** |
| | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ | ១៥.០០០.០០០ | ៤៣៦.៦៦៥ | ១៥.៤៣៦.៦៦៥ |
| ការដាក់ដើមទុនបន្ថែមក្នុងឆ្នាំ | ២៤.០០០.០០០ | - | ២៤.០០០.០០០ |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | ១.៣១២.៧៦៦ | ១.៣១២.៧៦៦ |
| **សមតុល្យគិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | **៣៩.០០០.០០០** | **១.៧៤៩.៤៣១** | **៤០.៧៤៩.៤៣១** |
| សមមូលជាពាន់រៀល *(មិនបានធ្វើសវនកម្ម)* | **១៥៧.៥២១.០០០** | **៧.០៦៥.៩៥២** | **១៦៤.៥៨៦.៩៥២** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ចាប់ពីទំព័រទី ១២ ដល់ ៦៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

| | | ២០១១ | ២០១០ | ២០១១ | ២០១០ |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | | (មិនបានធ្វើសវនកម្ម) | (មិនបានធ្វើសវនកម្ម) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | ២១ | ១.០២១.០៣៩ | ១២.៩១៧.១២២ | ៤.១២៣.៩៧៧ | ៥០.៧៣១.៨៩៤ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើធានាដើមទុន នៅធនាគារកណ្តាល | | (២.៤០០.០០០) | - | (៩.៦៩៣.៦០០) | - |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | (១៤.៥៨០.០០០) | (៩.៥០០.០០០) | (៥៨.៨៨៨.៦២០) | (៣៨.៥០៣.៥០០) |
| ប្រាក់បញ្ញើបម្រុង នៅធនាគារកណ្តាល | | (១.១១៥.០០០) | (៦១០.០០០) | (៤.៥០៣.៤៨៥) | (២.៤៧២.៣៣០) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១៣ | (៦២៥.២៥៦) | (១១២.៨៨៣) | (២.៥២៥.៤០៩) | (៤៥៧.៥១៥) |
| សាច់ប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ៣.៤៩៦ | - | ១៤.១២០ | - |
| ការទិញទ្រព្យសកម្មអរូបី | ១៤ | (៧៨.៤០៨) | (៧.៧៦៥) | (៣១៦.៦៩០) | (៣១.៤៧២) |
| **លំហូរសាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (១៨.៧៩៥.១៦៨) | (១០.២៣០.៦៤៨) | (៧៥.៩១៣.៦៨៤) | (៤១.៤៦៤.៨១៧) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការបង្កើនដើមទុន | | ២៤.០០០.០០០ | - | ៩៦.៩៣៦.០០០ | - |
| **លំហូរសាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | ២៤.០០០.០០០ | - | ៩៦.៩៣៦.០០០ | - |
| **កំណើនសុទ្ធ នៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ៦.២២៥.៨៧១ | ២.២៨៦.៤៧៤ | ២៥.១៤៦.២៩៣ | ៩.២៦៧.០៧៧ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ** | | ១៧.៥៩៨.៦៦១ | ១៥.៣១២.១៨៧ | ៧១.៣២៧.៣៧៤ | ៦៣.៨៣៦.៥០៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ | | - | - | (២៤៦.៣៨២) | (១.៧៧៦.២១១) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២០ | **២៣.៨២៤.៥៣២** | **១៧.៥៩៨.៦៦១** | **៩៦.២២៧.២៨៥** | **៧១.៣២៧.៣៧៤** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ចាប់ពីទំព័រទី ១២ ដល់ ៦៣ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១. ព័ត៌មានទូទៅ

ធនាគារ ភ្នំពេញ ពាណិជ្ជ (ហៅកាត់ថា "ធនាគារ") ត្រូវបានចុះបញ្ជីជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត លេខ Co-4898E/2008 ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ និងទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិ នៃកម្ពុជា ក្នុងការធ្វើប្រតិបត្តិការធនាគារ ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៨។

សកម្មភាពចម្បងៗរបស់ធនាគារ គឺការផ្តល់សេវាកម្មទូទៅផ្នែកធនាគារ និងសេវាកម្មផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ធនាគារមានការិយាល័យកណ្តាលមួយ និងសាខាចំនួនបី នៅរាជធានីភ្នំពេញ និង សាខាមួយទៀតនៅខេត្តសៀមរាប។

ការិយាល័យចុះបញ្ជីរបស់ធនាគារ មានទីតាំងបច្ចុប្បន្នស្ថិតនៅអគារលេខ ៧៦៧-៧៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានក្រុមប្រឹក្សាភិបាលអនុម័តឱ្យចេញផ្សាយ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១២។ ក្រុមប្រឹក្សាភិបាល មានសិទ្ធិក្នុងការកែប្រែ និងចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះឡើងវិញ។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជូនដូចខាងក្រោម។

### ២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំដោយអនុលោមទៅតាមគោលការណ៍ណែនាំ របស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS")។ ក្នុងការប្រើប្រាស់ស្តង់ដារគណនេយ្យកម្ពុជា ធនាគារក៏ បានប្រើប្រាស់ស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុកម្ពុជា CIFRS 7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ : ការលាតត្រដាងព័ត៌មាន"។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលនៃប្រតិបត្តិការនិងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេង ក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះ របាយការណ៍ហិរញ្ញវត្ថុទាំងនេះសម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់សន្ទិតកម្មតម្លៃដើម។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងទ្រព្យអកម្ម និងការលាតត្រដាងទ្រព្យសកម្ម និងទ្រព្យអកម្មយថាហេតុដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយ-ការណ៍ហិរញ្ញវត្ថុនេះ និងប៉ះពាល់ដល់ចំណូល និងចំណាយ ដែលបានរាយការណ៍នៅក្នុងការិយបរិច្ឆេទ។ ទោះបីជាការប៉ាន់ស្មានទាំងនេះ ពឹងផ្អែកលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រង ទៅលើព្រឹត្តិការណ៍ និង សកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យកម្រិតខ្ពស់បំផុត ឬភាពស្មុគស្មាញ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣។

អនុលោមតាមប្រកាសលេខ ធ៧-០៧-១៦៤ប្រ.ក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ របស់ធនាគារកណ្តាល តារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមភាគផ្លូវការ ដែលកំណត់ដោយធនាគារកណ្តាល នាកាលបរិច្ឆេទរាយការណ៍ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៣៩ រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ : ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៥៣ រៀល)។ តួលេខដែលបានប្តូរនេះ មិនត្រូវបានធ្វើសវនកម្មទេ ដូចនេះ មិនគួរបកស្រាយថាតួលេខនេះ ជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ

(ក) ស្តង់ដារថ្មីៗ វិសោធនកម្មលើស្តង់ដារដែលមានស្រាប់ និងបំណកស្រាយដែលចូលជាធរមានក្នុងឆ្នាំ ២០១១

ពុំមានស្តង់ដារគណនេយ្យថ្មីៗ ការធ្វើវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ និងបំណកស្រាយផ្សេងៗ ដែលបានចូលជាធរមាន នៅក្នុងដំណាច់ឆ្នាំហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ទេ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ (ត)

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ប៉ុន្តែពុំទាន់ចូលជាធរមាន

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ បានប្រកាសឱ្យប្រើប្រាស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទៅលើស្តង់ដារទាំងអស់ដែលបានបោះផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយផ្សេងៗ និងវិសោធនកម្ម ដែលអាចកើតឡើងនៅកាលៈទេសៈណាមួយ ទៅលើស្តង់ដារនីមួយៗដោយការបន្ថែមពាក្យ "កម្ពុជា"។ អង្គភាពគណនេយ្យសាធារណៈត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

ខាងក្រោមនេះ គឺជាស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIAS") ឬ CIFRS និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ហើយមានការពាក់ព័ន្ធ និងមានភាពចាំបាច់ចំពោះ សម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើម នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ប៉ុន្តែធនាគារមិនទាន់បានអនុវត្តមុនកាលកំណត់ទេ។

- CIAS 1 (វិសោធនកម្ម) ស្តីពី "ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ" ទាក់ទិននឹងចំណូលលម្អិតផ្សេងៗ

ការកែសម្រួលចម្បងនៃវិសោធនកម្មនេះ គឺតម្រូវឱ្យអង្គភាពទាំងឡាយធ្វើចំណាត់ថ្នាក់ខ្ទង់គណនីផ្សេងៗដែលបានបង្ហាញនៅក្នុង "ចំណូលលម្អិតផ្សេងៗ" តាមមូលដ្ឋានដែលអាចចាត់ថ្នាក់បានទៅក្នុងចំណេញ ឬខាត នៅពេលបន្ទាប់មក (និយ័តកម្មការធ្វើចំណាត់ថ្នាក់ឡើងវិញ)។ វិសោធនកម្មនេះ មិនបានគូសបញ្ជាក់ទេថាតើខ្ទង់គណនីណាខ្លះ ត្រូវបង្ហាញក្នុងចំណូលលម្អិតផ្សេងៗ។ ធនាគារមិនរំពឹងថាវិសោធនកម្មនេះ មានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ (ត)

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ប៉ុន្តែពុំទាន់ចូលជាធរមាន (ត)

- CIAS 16 (វិសោធនកម្ម) ស្តីពី "ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ" (និងវិសោធនកម្មបន្ទាប់លើ CIAS 7 ស្តីពី "របាយការណ៍លំហូរសាច់ប្រាក់")

ស្តង់ដារដែលបានធ្វើវិសោធនកម្មនេះ តម្រូវឱ្យអង្គភាពទាំងឡាយណា ដែលមានសកម្មភាពអាជីវកម្មប្រចាំថ្ងៃទាក់ទងទៅនឹងការជួល និងលក់ទ្រព្យសកម្មផ្សេងៗនៅពេលបន្ទាប់មក ត្រូវបង្ហាញសាច់ប្រាក់ដែលបានមកពីការលក់ទ្រព្យសកម្មទាំងនោះជា ប្រាក់ចំណូល ហើយត្រូវផ្ទេរតម្លៃនៅសល់របស់ទ្រព្យសកម្មនោះ ទៅជាសន្និធិវិញ នៅពេលដែលទ្រព្យសកម្មនោះ ត្រូវគេរៀបចំរួចរាល់សម្រាប់លក់។ វិសោធនកម្មនៅពេលបន្ទាប់មកទៀតទៅលើ CIAS 7 តម្រូវឱ្យចាត់ថ្នាក់លំហូរសាច់ប្រាក់ ដែលកើតពីការទិញ ការជួល និងការលក់ទ្រព្យសកម្មទាំងនោះ ជាលំហូរសាច់ប្រាក់បានមក ពីសកម្មភាពប្រតិបត្តិការ។ គេមិនរំពឹងថាស្តង់ដារនេះ នឹងមានផលប៉ះពាល់ជាសារវន្ត លើរបាយកាណ៍ហិរញ្ញវត្ថុរបស់ ធនាគារទេ។

- CIAS 19 ស្តីពី "អត្ថប្រយោជន៍និយោជិត"

កម្មវត្ថុនៃស្តង់ដារនេះគឺចែងអំពីគណនេយ្យកម្ម និងតម្រូវការក្នុងការលាតត្រដាង ពីអត្ថប្រយោជន៍និយោជិត។ ស្តង់ដារនេះតម្រូវឱ្យអង្គភាពមួយកត់ត្រាអត្ថប្រយោជន៍និយោជិតដូចតទៅ : (ក) កត់ត្រាជាទ្រព្យអកម្មនៅពេលដែលនិយោជិតបានផ្តល់សេវាកម្ម ដើម្បីទទួលបានអត្ថប្រយោជន៍តបស្នងមកវិញនាពេលអនាគត និង (ខ) កត់ត្រាជាចំណាយនៅពេលដែលអង្គភាពទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចដែលបានមកពីការផ្តល់សេវាកម្មរបស់និយោជិត ជាថ្នូរនឹងអត្ថប្រយោជន៍និយោជិត។

វិសោធនកម្មនាពេលបន្ទាប់មកលើស្តង់ដារនេះ គឺបានលុបចោលនូវវិធីសាស្ត្រប៉ាន់ស្មាន (corridor approach) ហើយគណនាចំណាយការប្រាក់តាមមូលដ្ឋានមូលនិធិសុទ្ធ។ ធនាគារមិនរំពឹងថាស្តង់ដារនេះមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ។

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ (ត)

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ប៉ុន្តែពុំទាន់ចូលជាធរមាន (ត)

- CIAS 24 (កែសម្រួល) ស្តីពី "ការលាតត្រដាងភាគីសម្ព័ន្ធញាតិ"

CIAS 24 ត្រូវបានកែសម្រួលដូចតទៅ ៖ (ក) កែសម្រួលនិយមន័យនៃពាក្យ "ភាគីសម្ព័ន្ធញាតិ" ឱ្យមានលក្ខណៈកាន់តែសាមញ្ញ ដោយបញ្ជាក់ឱ្យកាន់តែច្បាស់នូវអត្ថន័យរបស់វា និងលុបចោលនូវភាពមិនស៊ីសង្វាក់គ្នារបស់និយមន័យ និង (ខ) ផ្តល់នូវការលើកលែងចំពោះអង្គភាពដែលពាក់ព័ន្ធនឹងរដ្ឋាភិបាល ចំពោះតម្រូវការក្នុងការលាតត្រដាងភាគីសម្ព័ន្ធញាតិនេះ ។ ធនាគារមិនរំពឹងថាស្តង់ដារនេះមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

- CIAS 32 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ ៖ ការបង្ហាញ"

កម្មវត្ថុរបស់ស្តង់ដារនេះគឺដើម្បីបង្កើតគោលការណ៍ផ្សេងៗ សម្រាប់បង្ហាញពីឧបករណ៍ហិរញ្ញវត្ថុមួយចំនួន ជាទ្រព្យអកម្ម ឬមូលធន និងសម្រាប់ទូទាត់ទ្រព្យសកម្មហិរញ្ញវត្ថុ ជាមួយនឹងទ្រព្យអកម្មហិរញ្ញវត្ថុ ។ ស្តង់ដារនេះ ត្រូវអនុវត្តចំពោះការធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុទៅជាទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុ និងឧបករណ៍មូលធន ទៅតាមទស្សនៈវិស័យរបស់អ្នកចេញផ្សាយ ក៏ដូចជាការធ្វើចំណាត់ថ្នាក់ទៅលើអត្ថប្រយោជន៍ពាក់ព័ន្ធ ភាគលាភ ខាត និងចំណេញផងដែរ ។ ធនាគារមិនរំពឹងថាស្តង់ដារនេះ មានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារទេ ។

- CIAS 36 (វិសោធនកម្ម) ស្តីពី "ការថយចុះតម្លៃទ្រព្យសកម្ម"

ស្តង់ដារដែលបានធ្វើវិសោធនកម្មនេះបញ្ជាក់ថា ប្រសិនបើតម្លៃទីផ្សារដកចំណាយក្នុងការលក់ ត្រូវបានគេគណនាតាមមូលដ្ឋានលំហូរសាច់ប្រាក់អប្បហារ (discounted cash flows) នោះការបង្ហាញពីចំនួនដែលសមមូលនឹងតម្លៃទាំងនោះ សម្រាប់ការគណនាតម្លៃនៅប្រើប្រាស់ (value-in-use) គួរតែត្រូវបានធ្វើឡើង ។ ធនាគារមិនរំពឹងថាស្តង់ដារនេះមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

- CIAS 39 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ ៖ ការទទួលស្គាល់ និងការវាស់វែង"

ស្តង់ដារនេះបង្កើតនូវគោលការណ៍សម្រាប់ការទទួលស្គាល់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ទ្រព្យអកម្មហិរញ្ញវត្ថុ និងកិច្ចសន្យាមួយចំនួនក្នុងការទិញ ឬលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ។ ការអនុវត្ត CIAS 39 នេះ នឹងបណ្តាលឱ្យមានការកែប្រែគោលការណ៍គណនេយ្យលើឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដូចខាងក្រោម ៖

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ (ត)

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ប៉ុន្តែពុំទាន់ចូលជាធរមាន (ត)

- CIAS 39 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ : ការទទួលស្គាល់ និងការវាស់វែង" (ត)

ឥណទាន និងបុរេប្រទានអតិថិជន

បច្ចុប្បន្ននេះ គណនីឥណទាន និងបុរេប្រទានអតិថិជន ត្រូវបានរាយការណ៍នៅក្នុងតារាងតុល្យការ តាមសមតុល្យប្រាក់ដើមដែលនៅសល់ និងការប្រាក់ ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទានបាត់បង់។ ដោយឡែកក្រោម CIAS 39 គណនីឥណទាន និងគណនីអតិថិជន ត្រូវបានទទួលស្គាល់ជាបឋមតាមតម្លៃទីផ្សារ ដែលជាការចំណាយសាច់ប្រាក់ដើម្បីបង្កើត ឬទិញឥណទាន រាប់ទាំងចំណាយប្រតិបត្តិការផ្សេងៗផងដែរ ហើយបន្ទាប់មកវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ពិត។

ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ

បច្ចុប្បន្ននេះធនាគារអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដែលតម្រូវដោយប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ចេញដោយធនាគារកណ្តាល ដូចបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ២.៧ នៃរបាយការណ៍ហិរញ្ញវត្ថុ។ CIAS 39 តម្រូវឱ្យធនាគារវាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗ ទាំងតាមមូលដ្ឋាននៃការវាយតម្លៃទ្រព្យសកម្មទោល និងតាមមូលដ្ឋាននៃការវាយតម្លៃទ្រព្យសកម្មជាក្រុម ដើម្បីរកមើលថាតើមានភស្តុតាងពិតបង្ហាញថា មានការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុទោល និងទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមដែរឬទេ។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានវាស់វែងតាមចំនួនលម្អៀង រវាងតម្លៃនៅសល់នៃទ្រព្យសកម្មមួយ ធៀបនឹងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត (ដោយមិនគិតការខាតបង់ឥណទាននាពេលអនាគត ដែលមិនទាន់បានកើតឡើង) និងធ្វើអប្បហារផ្អែកលើអត្រាការប្រាក់ដើមពិតរបស់ទ្រព្យសកម្មនោះ។ ក្នុងការវាយតម្លៃរកការថយចុះតម្លៃជាក្រុម ទ្រព្យសកម្មទាំងឡាយត្រូវបានគេចាត់ជាក្រុម តាមមូលដ្ឋានទ្រព្យសកម្ម ដែលមានលក្ខណៈហានិភ័យឥណទានប្រហាក់ប្រហែលគ្នា។

ប្រាក់បញ្ញើរបស់អតិថិជន ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

បច្ចុប្បន្ននេះធនាគារវាស់វែងប្រាក់បញ្ញើរបស់ធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជនតាមចំនួនប្រាក់ដែលបានផ្ញើ។ CIAS 39 តម្រូវឱ្យវាស់វែងទ្រព្យអកម្មហិរញ្ញវត្ថុ (រាប់ទាំងប្រាក់បញ្ញើរបស់អតិថិជន) តាមតម្លៃថ្លៃដើមដករំលស់។

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ (ត)

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ប៉ុន្តែពុំទាន់ចូលជាធរមាន (ត)

<u>ចំណូលការប្រាក់ និងចំណាយការប្រាក់</u>

បច្ចុប្បន្ននេះធនាគារកត់ត្រា ចំណូលនិងចំណាយការប្រាក់តាមមូលដ្ឋានបង្គរ ទៅតាមអត្រាក្នុងកិច្ចសន្យា លើកលែងតែមានករណីសង្ស័យជាក់លាក់ណាមួយចំពោះការប្រមូលប្រាក់ ក្នុងករណីនេះការប្រាក់ត្រូវគេព្យួរទុកសិន រហូតដល់ពេលដែលគេទទួលបានសាច់ប្រាក់ជាក់ស្តែង។ CIAS 39 តម្រូវឱ្យកត់ត្រាចំណូលនិងចំណាយការប្រាក់នៃរាល់ឧបករណ៍ហិរញ្ញវត្ថុដែលមានការប្រាក់ទាំងអស់ ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ពិត។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុណាមួយ ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុមដែលមានលក្ខណៈស្រដៀងគ្នា ហើយបានថយចុះតម្លៃ ចំណូលការប្រាក់ត្រូវបានគេកត់ត្រាតាមអត្រាការប្រាក់ដែលបានប្រើក្នុងលំហូរសាច់ប្រាក់នាពេលអនាគត ដែលបានធ្វើអប្បហារ ដើម្បីវាស់វែងការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ។

- CIFRS 7 (វិសោធនកម្ម) ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ-ការលាតត្រដាងព័ត៌មាន"

ស្តង់ដារដែលបានកែសម្រួល តម្រូវឱ្យលាតត្រដាងការវាស់វែងតម្លៃទីផ្សារ និងហានិភ័យសាច់ប្រាក់ងាយស្រួលឱ្យបានកាន់តែប្រសើរឡើង។ ជាពិសេសវិសោធនកម្មនេះ តម្រូវឱ្យលាតត្រដាងការវាស់វែងតម្លៃទីផ្សារ ទៅតាមឋានានុក្រមនៃការវាស់វែងតម្លៃទីផ្សារ ដូចខាងក្រោម :

កម្រិតទី១ - តម្លៃដែលបានដាក់លក់ (មិនបានកែតម្រូវ) លើទីផ្សារសកម្ម នៃទ្រព្យសកម្ម និងទ្រព្យអកម្មដែលបានកំណត់។

កម្រិតទី២ - ធាតុចូល ក្រៅពីតម្លៃដាក់លក់ ដែលបានបញ្ចូលទៅក្នុងកម្រិតទី១ ហើយអាចអង្កេតទ្រព្យសកម្ម ឬទ្រព្យអកម្មបានដោយផ្ទាល់ ឬដោយប្រយោល និង

កម្រិតទី៣ - ធាតុចូលសម្រាប់ទ្រព្យសកម្ម ឬទ្រព្យអកម្ម ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន

និយតកម្មក្រោយមកទៀតលើស្តង់ដានេះ តំរូវអោយអង្គភាពធ្វើការលាតត្រដាងគុណភាព ដូចនឹងការលាតត្រដាងបរិមាណអំពីលក្ខណៈ និង ទំហំហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុ។ ធនាគារមិនរំពឹងថាស្តង់ដារនេះនឹងមាន ផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ ហិរញ្ញវត្ថុរបស់ធនាគារទេ។

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.២ ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយផ្សេងៗ (ត)

(ខ) ស្តង់ដារ និងវិសោធនកម្មលើស្តង់ដារដែលមានស្រាប់ ដែលបានចេញផ្សាយរួច ប៉ុន្តែពុំទាន់ចូលជាធរមាន (ត)

- CIFRS 9 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ"

CIFRS 9 គឺជាស្តង់ដារទីមួយដែលបានចេញផ្សាយ ជាផ្នែកនៃគម្រោងដ៏ទូលំទូលាយមួយ ដើម្បីជំនួស CIAS 39 ។ CIFRS 9 នៅរក្សាខ្លឹមសារដដែល ប៉ុន្តែបានសម្រួលគំរូនៃការវាស់វែងចម្រុះឱ្យមានលក្ខណៈសាមញ្ញ និងបង្កើតការវាស់វែងបឋមពីរប្រភេទ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺថ្លៃដើមរំលស់ និងតម្លៃទីផ្សារ ។ មូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់អាស្រ័យលើគំរូអាជីវកម្មរបស់អង្គភាព និងលក្ខណៈលំហូរសាច់ប្រាក់ជាប់កិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ។ គោលការណ៍ណែនាំក្នុង CIAS 39 លើការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និង Hedge Accounting នៅតែបន្តអនុវត្តដដែល ។ ធនាគារមិនទាន់បានវាយតម្លៃពីផលប៉ះពាល់ទាំងស្រុងនៃ CIFRS 9 ទេ ។

- CIFRS 13 ស្តីពី "ការវាស់វែងតម្លៃទីផ្សារ"

CIFRS13 មានគោលដៅកែលម្អភាពស៊ីសង្វាក់គ្នា និងកាត់បន្ថយភាពស្មុគស្មាញ ដោយផ្តល់និយមន័យជាក់លាក់លើតម្លៃទីផ្សារ និងប្រភពទោលនៃការវាស់វែងតម្លៃទីផ្សារ ព្រមទាំងតម្រូវការក្នុងការលាតត្រដាងសម្រាប់ប្រើប្រាស់ក្នុង CIFRSs ។ តម្រូវការផ្សេងៗ ដែលមានភាពស្របគ្នាភាគច្រើនរវាង CIFRSs និង US GAAP មិនបានពង្រីកការប្រើប្រាស់គណនេយ្យកម្មតម្លៃទីផ្សារទេ ប៉ុន្តែបានផ្តល់នូវគោលការណ៍ណែនាំអំពីវិធីសាស្ត្រដែលគួរអនុវត្តនៅពេលដែលការប្រើប្រាស់របស់វាត្រូវបានអនុញ្ញាតដោយស្តង់ដារផ្សេងៗ នៅក្នុង IFRSs ឬ US GAAP ។ ធនាគារមិនរំពឹងថាស្តង់ដារនេះមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារទេ ។

ក្រៅពីការកែលម្អ និងវិសោធនកម្មផ្សេងៗលើស្តង់ដារដែលមានស្រាប់ដូចមានចែងខាងលើ ស្តង់ដារផ្សេងៗ វិសោធនកម្មនានា និងបំណកស្រាយលើស្តង់ដារដែលមានស្រាប់ផ្សេងទៀត ដែលបានចេញផ្សាយរួចហើយ ហើយត្រូវអនុវត្តសម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ មិនពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារទេ ។

(គ) ការអនុវត្តស្តង់ដារគណនេយ្យមុនកាលកំណត់

ក្នុងឆ្នាំ២០១១ ធនាគារមិនបានអនុវត្តស្តង់ដារគណនេយ្យថ្មីៗ ឬស្តង់ដារគណនេយ្យដែលបានកែសម្រួល មុនកាលកំណត់នោះទេ ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៣ ប្រតិបត្តិការរូបិយប័ណ្ណបរទេស

#### ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណបង្ហាញ

គណនីទាំងអស់ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយ-ប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណបង្ហាញរបស់ធនាគារ ។

#### ខ. ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពី ប្រតិបត្តិការទាំងនេះ និងពីការប្តូរទ្រព្យសកម្ម និងទ្រព្យអកម្មរូបិយវត្ថុជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក តាមអត្រានាដំណាច់ឆ្នាំ ត្រូវបានគេកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

### ២.៤ ចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់ពីឥណទាន និងបុរេប្រទានអតិថិជន ប្រាក់បញ្ញើនៅធនាគារកណ្តាល និងធនាគារផ្សេងៗ ត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានបង្គរ លើកលែងតែមានការមន្ទិលសង្ស័យជាក់លាក់ពីលទ្ធភាពនៃការប្រមូលឥណទាន និងបុរេប្រទានអតិថិជន ក្នុងករណីនេះចំណូលការប្រាក់មិនត្រូវបានគេកត់ត្រាទេ។ គោលការណ៍ព្យួរការប្រាក់របស់ធនាគារ គឺអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ស្តីពីការព្យួរការប្រាក់លើឥណទានមិនដំណើរការ និងសំវិធានសំរាប់ការខាតបង់ពីឥណទាន និងបុរេប្រទានអតិថិជន។

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ ។

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ ចំណូលកម្រៃ និងជើងសារ

ចំណូលកម្រៃ និងជើងសារ រួមមានចំណូលទទួលបានពីការផ្ទេរមូលនិធិចេញ-ចូល ប្រតិបត្តិការប័ណ្ណឥណទាន លិខិតធានាផ្សេងៗ កំរៃនៃការរៀបចំឥណទាន ចំណូលពីការបម្រើសេវាកម្ម និងកម្រៃដំណើរការ និងចំណូលផ្សេងៗ។

កម្រៃដំណើរការឥណទាន ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល នៅពេលប្រគល់ឥណទានទៅអតិថិជន។

កម្រៃពីការផ្ទេរមូលនិធិចេញ-ចូល ប្រតិបត្តិការប័ណ្ណឥណទាន លិខិតធានាផ្សេងៗ និងកម្រៃសេវាកម្មផ្សេងៗ ទៅឱ្យអតិថិជន ត្រូវបានកត់ត្រាជាចំណូលក្នុងឆ្នាំ នៅពេលដែលសេវាកម្មត្រូវបានបំពេញឱ្យអតិថិជន។

### ២.៦ ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានអតិថិជន ត្រូវបានកត់ត្រាក្នុងតារាងតុល្យការ នូវសមតុល្យទឹកប្រាក់ដើមដែលនៅសល់ ដកចំនួនដែលបានជំរះចេញពីបញ្ជី ព្រមទាំងសំវិធានធនឥណទានអាក្រក់ និងសង្ស័យ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលគ្មានលទ្ធភាពជាក់លាក់ថានឹងអាចប្រមូលបានមកវិញ។ ឥណទាននិងបុរេប្រទានអតិថិជន ដែលប្រមូលបានមកវិញក្រោយពេលត្រូវបានជម្រះចេញពីបញ្ជី ឬក្រោយពេលបានធ្វើសំវិធានធន ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.៧ សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ និងបុរេប្រទានអតិថិជន

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដែលតម្រូវដោយប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ចេញដោយធនាគារកណ្តាល។ ប្រកាសនេះ តម្រូវឱ្យធនាគារពាណិជ្ជកម្មទាំងអស់ ធ្វើចំណាត់ថ្នាក់ឥណទាន និងបុរេប្រទាន និងទ្រព្យសកម្មស្រដៀងគ្នា ទៅជា៥ថ្នាក់ ។ កម្រិតអប្បបរមានៃសំវិធានធនឥណទានបាត់បង់ ត្រូវបានធ្វើឡើងអាស្រ័យទៅតាមចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតពីទ្រព្យសកម្មផ្សេងៗ (លើកលែងតែសាច់ប្រាក់) ដែលបានដាក់ជាវត្ថុបញ្ចាំ មានដូចខាងក្រោម ៖

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៧ សំវិធានធនសម្រាប់ឥណទានអាក្រក់ និងសង្ស័យ និងបុរេប្រទានអតិថិជន (ត)

| *សំវិធានធនទូទៅ* | **អត្រាសំវិធានធន** |
|---|---|
| ស្តង់ដារ | ១% |
| *សំវិធានធនជាក់លាក់* | |
| ឃ្លាំមើល | ៣% |
| ក្រោមស្តង់ដារ | ២០% |
| សង្ស័យ | ៥០% |
| បាត់បង់ | ១០០% |

### ២.៨ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណា ដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានគេធ្វើរំលស់ទេ និងត្រូវបានគេត្រួតពិនិត្យប្រចាំឆ្នាំ រកការថយចុះតម្លៃរបស់វា។ បណ្តាទ្រព្យសកម្មដែលត្រូវធ្វើរំលស់ ត្រូវបានគេត្រួតពិនិត្យដើម្បីកំណត់រកការថយចុះតម្លៃរបស់វា នៅពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយ ចង្អុលបង្ហាញថាតម្លៃនៅសល់នឹងមិនអាចប្រមូលមកវិញបាន។ ការខាតបង់មកពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រាតាមចំនួនលម្អៀង រវាងតម្លៃនៅសល់នៃទ្រព្យសកម្មនោះ លើសតម្លៃដែលអាចប្រមូលបានមកវិញ។ តម្លៃដែលអាចប្រមូលបានមកវិញ គឺ ជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃទីផ្សារនៃទ្រព្យសកម្មនោះ ដកចំណាយក្នុងការលក់ និងតម្លៃកំពុងប្រើប្រាស់។

ការខាតបង់ពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រាក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលវាបានកើតឡើង។ ការកត់ត្រាបញ្ច្រាសមកវិញនៃការខាតបង់ពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រានៅក្នុងរបាយកាណ៍លទ្ធផល ទៅតាមទំហំតម្លៃនៅសល់នៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃនៅសល់ដែលបានកំណត់ កាត់កងនឹងរំលស់ ប្រសិនបើគេមិនធ្លាប់បានកត់ត្រាការខាតបង់ពីការថយចុះតម្លៃនោះទេ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់ និងការខាតបង់ពីការថយចុះតម្លៃបង្គរ។ ថ្លៃដើមរួមមាន ចំណាយ ផ្ទាល់ផ្សេងៗ ដែលបានចំណាយក្នុងការទិញទ្រព្យនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃចុះបញ្ជីនៃទ្រព្យនោះ ឬត្រូវបានគេកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែកតាមជាក់ស្តែង តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះ នឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានគេវាស់ស្ទង់គួរឱ្យជឿជាក់បានប៉ុណ្ណោះ។ ចំណាយជួសជុល និងថែទាំផ្សេងៗទៀត ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែល ប្រតិបត្តិការនោះកើតឡើង។

ការធ្វើរំលស់លើទ្រព្យសម្បត្តិនិងបរិក្ខារផ្សេងៗ ត្រូវបានគណនាជាបន្ទុកទៅក្នុងរបាយការណ៍លទ្ធផលដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យនោះ ដូចខាងក្រោម :

| | |
|---|---|
| ការកែលម្អអគារ | ២០% |
| គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់ | ២៥% |
| បរិក្ខារកុំព្យូទ័រ | ៥០% |
| យានយន្ត | ២៥% |

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យ និងសម្រួលឡើងវិញតាមការជាក់ស្តែង នាកាលបរិច្ឆេទតារាងតុល្យការនីមួយៗ។

ប្រសិនបើតម្លៃនៅសល់របស់ទ្រព្យសកម្មណាមួយ លើសពីតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាម ឱ្យនៅស្មើនឹងចំនួនដែលអាចប្រមូលមកវិញបាន។

ចំណេញ ឬខាតពីការលក់ជម្រះទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃនៅសល់ ហើយចំណេញ ឬខាតនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

#### ២.១០ ទ្រព្យសកម្មអរូបី

*កម្មវិធីកុំព្យូទ័រ និងកម្មវិធីស្វីហ្វ (swift software)*

ទ្រព្យសកម្មអរូបី រួមមានកម្មវិធីកុំព្យូទ័រ (Moneta) និងកម្មវិធីស្វីហ្វ *(swift software)* ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់រូបី និងការខាតបង់ពីការថយចុះតម្លៃ ប្រសិនបើមាន។

រំលស់រូបី ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានរំលស់ថេរ លើអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មនីមួយៗ តាមអត្រាខាងក្រោម ៖

| | |
|---|---|
| កម្មវិធីកុំព្យូទ័រ (Moneta) | ២០% |
| កម្មវិធីកុំព្យូទ័រ (swift software) | ៥០% |

#### ២.១១ ពន្ធពន្យារ និងពន្ធលើប្រាក់ចំណេញ

បន្ទុកពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ ត្រូវបានគណនាតាមមូលដ្ឋានច្បាប់ពន្ធដារ ដែលបានអនុម័តរួចរាល់ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ក្នុងព្រះរាជាណាចក្រកម្ពុជា ជាទីកន្លែងដែលធនាគារធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារលើប្រាក់ចំណេញ នឹងត្រូវកត់ត្រាទាំងស្រុង ដោយប្រើវិធីសាស្ត្រទ្រព្យអកម្ម លើលម្អៀងបណ្តោះអាសន្នដែលកើតមាន រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម និងតម្លៃនៅសល់របស់ទ្រព្យសកម្ម និងទ្រព្យអកម្មទាំងនោះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានគេកត់ត្រា លុះត្រាតែមានភាពប្រាកដថា នឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដើម្បីកាត់កងលម្អៀងបណ្តោះអាសន្ននោះ។

#### ២.១២ ភតិសន្យាប្រតិបត្តិ

ភតិសន្យា ដែលភាគីម្ចាស់ទ្រព្យនៅមានចំណែកហានិភ័យ និងផលកម្មសិទ្ធិជាសារវន្ត ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៣ សំវិធានធន

សំវិធានធន ត្រូវបានកត់ត្រានៅពេលដែលធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលធនាគារបានបង្កើតឡើងនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល។ វាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានបានយ៉ាងគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន ភវនីយភាពដែលតម្រូវឱ្យមានចំណាយដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់កាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាមានភវនីយភាពនៃការចំណាយមួយ នៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានគណនាតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ន នៃតម្លៃគិតតាមពេលវេលាទឹកប្រាក់ និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធន ដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

### ២.១៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ គណនីចរន្តនៅធនាគារកណ្តាល សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដែលមានការកំណត់រយៈពេល ៣ខែ រឺតិចជាងនេះ គិតពីថ្ងៃចាប់ផ្តើម។

### ២.១៥ ប្រតិបត្តិការភាគីសម្ព័ន្ធញាតិ

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីសម្ព័ន្ធញាតិត្រូវបានគេឱ្យនិយមន័យថា ជាភាគីដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងហោចណាស់ ១០% នៃដើមទុន ឬសិទ្ធិបោះឆ្នោត ព្រមទាំងបុគ្គលទាំងឡាយណា ដែលចូលរួមក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

### ២.១៦ តួលេខប្រៀបធៀប

នៅពេលដែលមានភាពចាំបាច់ តួលេខប្រៀបធៀបត្រូវបានកែតម្រូវ ដើម្បីឱ្យស្របទៅតាមបម្រែបម្រួលក្នុងការបង្ហាញក្នុងឆ្នាំបច្ចុប្បន្ន។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៧ តួលេខគត់

បណ្តាតួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានគេកាត់ខ្ទង់គត់ចំពោះតួលេខជាប្រាក់ដុល្លារអាមេរិក និងកាត់ខ្ទង់គត់ពាន់រៀល ចំពោះតួលេខជាប្រាក់រៀល ។

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ធនាគារធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលប៉ះពាល់លើចំនួនទ្រព្យសកម្ម និងទ្រព្យអកម្មដែលបានរាយការណ៍ ។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ។

### ក. ការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃឥណទាន និងបុរេប្រទាន

ធនាគារ បានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទានសំខាន់ៗ និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ៧-០៩-០៧៤ប្រ.ក. ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ។ ធនាគារកណ្តាលតម្រូវអោយធនាគារពាណិជ្ជទាំងឡាយ ធ្វើចំណាត់ថ្នាក់ឥណទាន និងបុរេប្រទានរបស់ខ្លួន ព្រមទាំងទ្រព្យសកម្មស្រដៀងគ្នាជាប្រាំថ្នាក់ ហើយត្រូវចាំបាច់ធ្វើសំវិធានធនអប្បបរមាទៅតាមថ្នាក់និមួយៗដោយពុំគិតពីទ្រព្យបញ្ចាំឡើយ ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន តម្រូវឱ្យធនាគារគិតពិចារណាទៅលើបទពិសោធន៍ក្នុងការសងប្រាក់កន្លងមករបស់អ្នកខ្ចី និងវាយតម្លៃទៅលើលក្ខខណ្ឌ ហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់ផងដែរ ។

### ខ. ពន្ធលើប្រាក់ចំណេញ

ពន្ធ ត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ន នៃបទប្បញ្ញត្តិពន្ធដារ ។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងអស់នេះ មានការផ្លាស់ប្តូរពីគ្រាមួយទៅគ្រាមួយ ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង ភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនលើពន្ធពន្យារនៅក្នុងការិយបរិច្ឆេទ ដែលការកំណត់ពន្ធបានធ្វើឡើង ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ៤. ចំណូលការប្រាក់

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ឥណទាន និងបុរេប្រទានអតិថិជន | ៣.៨៩៣.៣៩៤ | ២.២៨៦.៥៨៩ | ១៥.៧២៥.៤១៨ | ៩.២៦៧.៥៤៥ |
| សមតុល្យនៅធនាគារកណ្តាល | ២.៦៤៧ | ២.៦៥០ | ១០.៦៩១ | ១០.៧៤០ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៦៦៤.៨២៧ | ៧០៣.៥៦២ | ២.៦៨៥.២៣៦ | ២.៨៥១.៩៣៧ |
| | ៤.៥៦០.៨៦៨ | ២.៩៩២.៨០១ | ១៨.៤២១.៣៤៥ | ១២.១២៩.៨២២ |

## ៥. ចំណាយការប្រាក់

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ប្រាក់បញ្ញើសន្សំ | ៩៨.០៤៨ | ៧៤.៨៧៣ | ៣៩៦.០១៦ | ៣០៣.៤៦០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.២១៩.៤៦៨ | ៩៩៦.៥១១ | ៤.៩២៥.៤៣១ | ៤.០៣៨.៨៥៩ |
| ប្រាក់បញ្ញើតាមដំណាក់កាល | ៨.១៦៩ | ៣.២៨២ | ៣២.៩៩៥ | ១៣.៣០២ |
| | ១.៣២៥.៦៨៥ | ១.០៧៤.៦៦៦ | ៥.៣៥៤.៤៤២ | ៤.៣៥៥.៦២១ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ៦. ចំណូលកម្រៃ និងជើងសារ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| កម្រៃដំណើរការផ្តល់ឥណទាន | ៤៤៧.១០៩ | ២៥៩.០៤៧ | ១.៨០៥.៨៧៣ | ១.០៤៩.៩១៧ |
| កម្រៃពីសេវាផ្ទេរប្រាក់ | ១៩០.០០០ | ១៩៣.០០០ | ៧៦៧.៤១០ | ៧៨២.២២៩ |
| កម្រៃពិន័យ | ១០២.៨២៤ | ៧៧.៩៩៦ | ៤១៥.៣០៦ | ៣១៦.១១៨ |
| កម្រៃការផ្ទេរប្រាក់ចេញ-ចូល | ៨៥.៧៧០ | ៤០.៣៦០ | ៣៤៦.៤២៥ | ១៦៣.៥៧៩ |
| កម្រៃធានា | ១៨.៣២៧ | ៩.៥៧០ | ៧៤.០២៣ | ៣៨.៧៨៧ |
| កម្រៃកិច្ចសន្យា | ៨.៥៥៦ | ៣.៨៧០ | ៣៤.៥៥៨ | ១៥.៦៨៥ |
| កម្រៃផ្សេងៗ | ៨៦.៩០០ | ៣៨.៩៩៧ | ៣៥០.៩៨៩ | ១៥៦.៤៣៤ |
| | ៩៣៩.៤៨៦ | ៦២២.៤៤០ | ៣.៧៩៤.៥៨៤ | ២.៥២២.៧៤៩ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ៧. ចំណាយទូទៅ និងរដ្ឋបាល

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ចំណាយបុគ្គលិក និងចំណាយពាក់ព័ន្ធផ្សេងៗ | ៨៥៦.០៩៨ | ៥៨០.៦៦៥ | ៣.៤៥៧.៧៨០ | ២.៣៥៣.៤៣៥ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់១៣) | ៣២៤.៣៧៦ | ៣១០.០៤៣ | ១.៣១០.១៥៥ | ១.២៥៦.៦០៤ |
| រំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់១៤) | ៨៩.៦៩៤ | ៩៩.៣៩២ | ៣៦២.២៧៤ | ៤០២.៨៣៦ |
| ចំណាយលើការជួល | ២០៣.៣៤០ | ១១៤.៨០៨ | ៨២១.២៩០ | ៤៦៥.៣១៧ |
| ចំណាយលើម្ហូបអាហារ និងការកំសាន្ត | ៩០.៧៧៨ | ៥៣.៨៨៥ | ៣៦៦.៦៥២ | ២១៨.៣៩៦ |
| ចំណាយកម្រៃអ្នកជំនាញ | ៧០.៩១២ | ៦៩.១០៩ | ២៨៦.៤១៤ | ២៨០.០៩៩ |
| ចំណាយលើការជួសជុល និងការថែទាំ | ៦៧.៤២៧ | ៥៧.៦១៧ | ២៧២.៣៣៨ | ២៣៣.៥២២ |
| ចំណាយទឹក ភ្លើង | ៥៨.៨២៧ | ៤៦.៦៩៣ | ២៣៧.៦០២ | ១៨៩.២៤៧ |
| ចំណាយផ្នែកទីផ្សារ និងការផ្សព្វផ្សាយ | ៥៧.៧៣៤ | ៣៣.៤៨៥ | ២៣៣.១៨៨ | ១៣៥.៧១៥ |
| ចំណាយលើការដឹកជញ្ជូន | ៥៣.២១៩ | ៤៣.០២២ | ២១៤.៩៥២ | ១៧៤.៣៦៨ |
| ចំណាយលើសម្ភារៈការិយាល័យ | ៥២.៨៦៨ | ៤២.៣៤៨ | ២១៣.៥៣៤ | ១៧១.៦៣៦ |
| ចំណាយលើសន្តិសុខអគារ | ៤៦.១០១ | ២៧.៣៩០ | ១៨៦.២០២ | ១១១.០១២ |
| កម្រៃអាជ្ញាប័ណ្ណធនាគារ | ៤៤.៩៨៧ | ៣០.៤៩៥ | ១៨១.៧០២ | ១២៣.៥៩៦ |
| ចំណាយលើការធ្វើដំណើរ និងការទំនាក់ទំនង | ៣៧.៣៩៦ | ៣២.៤៤២ | ១៥១.០៤២ | ១៣១.៤៨៧ |
| ចំណាយលើសន្និបាត និងសន្និសីទ | ៣៦.៨៩៣ | ១៤.២៨៣ | ១៤៩.០១១ | ៥៧.៨៨៩ |
| ចំណាយសេវាធនាគារ | ២៧.០៥០ | ៧.២១៨ | ១០៩.២៥៥ | ២៩.២៥៥ |
| ចំណាយឥណទានខាតជំរះចេញពីបញ្ជី | ១៨.៧៩៦ | ៣០.០០០ | ៧៥.៩១៧ | ១២១.៥៩០ |
| ចំណាយលើធានារ៉ាប់រង | ១០.២៥៥ | ៩.១០២ | ៤១.៤២០ | ៣៦.៨៩០ |
| ចំណាយពន្ធផ្សេងៗ | ៩៨.៦៨៦ | ៦១.៣១៤ | ៣៩៨.៥៩៣ | ២៤៨.៥០៦ |
| ចំណាយផ្សេងៗ | ៦៦.៥៥៤ | ៣៨.៥៩៥ | ២៦៨.៨១២ | ១៥៦.៤២៦ |
| | ២.៣១១.៩៩១ | ១.៧០១.៩០៦ | ៩.៣៣៨.១៣៣ | ៦.៨៩៧.៨២៦ |

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ៨. ចំណាយពន្ធលើប្រាក់ចំណេញ

#### ក. ពន្ធលើប្រាក់ចំណេញ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ពន្ធលើប្រាក់ចំណេញចរន្ត | ៣៦៤.៤២៩ | ១៣៣.៩៩៤ | ១.៤៧១.៩២៩ | ៥៤៣.០៧៨ |
| | ៣៦៤.៤២៩ | ១៣៣.៩៩៤ | ១.៤៧១.៩២៩ | ៥៤៣.០៧៨ |

#### ខ. បម្រែបម្រួលពន្ធពន្យារទ្រព្យអកម្ម

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| សមតុល្យនាដើមគ្រា | ១០១.៤៤៨ | ២.៩៤៤ | ៤០៩.៧៤៨ | ១០.៣១១ |
| ពន្ធលើប្រាក់ចំណេញ | ៣៦៤.៤២៩ | ១៣៣.៩៩៤ | ១.៤៧១.៩២៩ | ៥៤៣.០៧៨ |
| ពន្ធលើប្រាក់ចំណេញបានបង់ | (១៥៣.៨៨៥) | (៣៥.០៩០) | (៦២១.៥៤២) | (១៤២.២២០) |
| សមតុល្យនាចុងគ្រា | ៣១១.៩៩២ | ១០១.៤៤៨ | ១.២៦០.១៣៥ | ៤១១.១៦៩ |

#### គ. ពន្ធសាជីវកម្ម (លើប្រាក់ចំណេញ) ត្រូវបានគណនាដូចខាងក្រោម ៖

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ចំណេញមុនបង់ពន្ធ | ១.៦៧៧.១៩៥ | ៧២៨.១៧៤ | ៦.៧៧៤.១៨៨ | ២.៩៥១.២៨៨ |
| ពន្ធគណនាតាមអត្រា ២០% | ៣៣៥.៤៣៩ | ១៤៥.៦៣៥ | ១.៣៥៤.៨៣៨ | ៥៩០.២៥៨ |
| *ចំណាយដែលមិនអាចកាត់កងបាន ២០%* | | | | |
| ផលប៉ះពាល់នៃចំណាយដែលមិនអាចកាត់កងបាន | ២៨.៩៩០ | (១១.៦៤១) | ១១៧.០៩១ | (៤៧.១៨០) |
| ពន្ធលើប្រាក់ចំណេញ | ៣៦៤.៤២៩ | ១៣៣.៩៩៤ | ១.៤៧១.៩២៩ | ៥៤៣.០៧៨ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ៨. ចំណាយពន្ធលើប្រាក់ចំណេញ (ត)

### ឃ. ពន្ធអប្បបរមា

ពន្ធលើប្រាក់ចំណេញរបស់ធនាគារ ត្រូវបានគណនាដោយផ្អែកលើពន្ធអប្បបរមា។ ពន្ធអប្បបរមា ត្រូវបានគណនាតាមអត្រា ១% នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលរាល់ពន្ធទាំងអស់។ ពន្ធលើប្រាក់ចំណេញ ត្រូវបង់តាមអត្រាណាមួយខាងក្រោមនេះ :

- ២០% លើប្រាក់ចំណេញជាប់ពន្ធ ឬ
- ពន្ធអប្បបរមា ១%នៃផលរបរសរុប រួមបញ្ចូលអាករលើតម្លៃបន្ថែម ដែលមានអត្រាខ្ពស់ជាង។

### ង. បញ្ហាពន្ធផ្សេងៗ

លិខិតប្រកាសពន្ធរបស់ធនាគារ ត្រូវត្រួតពិនិត្យដោយនាយកដ្ឋានពន្ធដារតាមការិយបរិច្ឆេទ។ ដោយសារផ្នែកខ្លះនៃច្បាប់ និងបទប្បញ្ញត្តិពន្ធដារ អាចមានបំណកស្រាយខុសៗគ្នា ហេតុនេះចំនួនពន្ធដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចមានការផ្លាស់ប្តូរនៅពេលក្រោយ អាស្រ័យលើការកំណត់ចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ។

## ៩. សមតុល្យនៅធនាគារកណ្តាល

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ប្រាក់តម្កល់ធានាដើមទុន (i) | ៣.៩០០.០០០ | ១.៥០០.០០០ | ១៥.៧៥២.១០០ | ៦.០៧៥.៥០០ |
| ប្រាក់តម្កល់បម្រុងកាតព្វកិច្ច (ii) | ២.៤៥២.០០០ | ១.៣៣៧.០០០ | ៩.៩០៣.៦២៨ | ៥.៤១៨.៨៦១ |
| គណនីចរន្ត (iii) | ៥.២៩៣.៧៦៩ | ២.៥២៧.២៣៧ | ២១.៣៨១.៥៣៣ | ១០.២៤២.៨៩២ |
| | ១១.៦៤៥.៧៦៩ | ៥.៣៦៤.២៣៧ | ៤៧.០៣៧.២៦១ | ២១.៧៤១.២៥៣ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ៩. សមតុល្យនៅធនាគារកណ្តាល (ត)

(i) អនុលោមតាមប្រកាសលេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ធនាគារត្រូវរក្សាប្រាក់តម្កល់ធានាដើមទុន នៅធនាគារកណ្តាល ចំនួន ៣.៩០០.០០០ ដុល្លារអាមេរិក តំណាងឱ្យ ១០% នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំក្នុងចន្លោះពី០,១០%-០,១១%ក្នុងមួយឆ្នាំ។ ប្រាក់តម្កល់ធានាដើមទុនទាំងនេះ នឹងត្រូវបង្វិលមកឱ្យធនាគារវិញ ប្រសិនបើធនាគារបញ្ចប់ប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយប្រាក់តម្កល់នេះ មិនអាចយកមកប្រើប្រាស់សម្រាប់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារបានទេ។

(ii) ប្រាក់បញ្ញើបម្រុង គឺជាទុនបម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា ៨% ចំពោះប្រាក់រៀល និង ១២% ចំពោះរូបិយប័ណ្ណបរទេសផ្សេងៗ នៃប្រាក់បញ្ញើសរុបរបស់អតិថិជន និងគណនីផាត់ទាត់ជាមួយធនាគារផ្សេងៗ។ ៤%នៃទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើអតិថិជនជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំក្នុងចន្លោះពី ០.០៩%-០.១៤% ទន្ទឹមនឹងនោះ ទុនបម្រុងកាតព្វកិច្ច ៨% ទៀត និងទុនបម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើអតិថិជនជាប្រាក់រៀល ពុំមានការប្រាក់ទេ។

(iii) គណនីចរន្តនេះ គឺជាគណនីដែលមិនមានការប្រាក់។

## ១០. ប្រាក់បញ្ញើ និងប្រាក់តំកល់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ធនាគារក្នុងស្រុក : | | | | |
| គណនីចរន្ត | ១៤.៩៧៥ | ១៥.៦៣៥ | ៦០.៤៨៤ | ៦៣.៣៦៩ |
| គណនីសន្សំ | ១.៤១៨.៨១៣ | ១.៧៧២.៥០៣ | ៥.៧៣០.៥៨៦ | ៧.១៨៣.៩៥៥ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៣៧.០៨០.០០០ | ២០.០០០.០០០ | ១៤៩.៧៦៦.១២០ | ៨១.០៦០.០០០ |
| ធនាគារក្រៅស្រុក : | | | | |
| គណនីចរន្ត | ២.៣៣៩.៧៤៧ | ៣.០៤៧.៤៥០ | ៩.៤៥០.២៣៨ | ១២.៣៥១.៣១៥ |
| | ៤០.៨៥៣.៥៣៥ | ២៤.៨៣៥.៥៨៨ | ១៦៥.០០៧.៤២៨ | ១០០.៦៥៨.៦៣៩ |

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ១០. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ (ត)

គណនីចរន្តនៅធនាគារក្នុងស្រុក និងក្រៅស្រុក មិនមានការប្រាក់ទេ។

ប្រាក់បញ្ញើមានកាលកំណត់ និងគណនីសន្សំ ទទួលបានការប្រាក់ក្នុងចន្លោះពី ១% ទៅ ៥,១០% (២០១០: ១% ទៅ ៦%) និង ០,៧៥% (២០១០ : ០,៧៥%) ក្នុងមួយឆ្នាំ។ អាយុកាលរបស់ប្រាក់បញ្ញើមានកាលកំណត់ ត្រូវបានវិភាគដូចខាងក្រោម :

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ចន្លោះពី ១ ខែ ទៅ ៣ ខែ | ១០.៥០០.០០០ | ៨.០០០.០០០ | ៤២.៤០៩.៥០០ | ៣២.៤២៤.០០០ |
| ចន្លោះពី ៤ ខែ ទៅ ១២ ខែ | ២៦.៥៨០.០០០ | ១២.០០០.០០០ | ១០៧.៣៥៦.៦២០ | ៤៨.៦៣៦.០០០ |
| | ៣៧.០៨០.០០០ | ២០.០០០.០០០ | ១៤៩.៧៦៦.១២០ | ៨១.០៦០.០០០ |

### ១១. ឥណទាន និងបុរេប្រទានអតិថិជន

#### (ក) វិភាគតាមប្រភេទឥណទាន

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ឥណទានវិបារូបន៍ | ៤.១១៦.៧៥៨ | ១.៨៨៥.៩៩៦ | ១៦.៦២៧.៥៨៦ | ៧.៦៤៣.៩៤២ |
| ឥណទាន និងបុរេប្រទានអតិថិជន | | | | |
| ឥណទានរយៈពេលវែង | ១៨.៣៩៤.៦០៣ | ៧.៨៨១.០៦៨ | ៧៤.២៩៥.៨០២ | ៣១.៩៤១.៩៦៩ |
| ឥណទានរយៈពេលខ្លី | ២០.៧៨៣.៧៧២ | ១៤.៩៧៩.៩០០ | ៨៣.៩៤៥.៦៥៥ | ៦០.៧១៣.៥៣៥ |
| | ៤៣.២៩៥.១៣៣ | ២៤.៧៤៦.៩៦៤ | ១៧៤.៨៦៩.០៤៣ | ១០០.២៩៩.៤៤៦ |
| សំវិធានធនឥណទាន និងបុរេប្រទាន អតិថិជនអាក្រក់ និងសង្ស័យ | | | | |
| សំវិធានធនជាក់លាក់ | - | - | - | - |
| សំវិធានធនទូទៅ | (៤៣២.៩៥២) | (២៤៧.៤៦៩) | (១.៧៤៨.៦៩៣) | (១.០០២.៩៥២) |
| | ៤២.៨៦២.១៨១ | ២៤.៤៩៩.៤៩៥ | ១៧៣.១២០.៣៥០ | ៩៩.២៩៦.៤៩៤ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១១. ឥណទាន និងបុរេប្រទានអតិថិជន (ត)

### (ក) វិភាគតាមប្រភេទឥណទាន (ត)

បម្រែបម្រួលក្នុងសំវិធានធនឥណទាន និងបុរេប្រទានអតិថិជនអាក្រក់ និងសង្ស័យ មានដូចខាងក្រោម ៖

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| នាដើមឆ្នាំ | ២៤៧.៤៦៩ | ១៣៦.៩៧៤ | ១.០០២.៩៩២ | ៥៧១.០៤៥ |
| សំវិធានធនបន្ថែមក្នុងឆ្នាំ | | | | |
| សំវិធានធនជាក់លាក់ | ១៨៥.៤៨៣ | ១១០.៤៩៥ | ៧៤៩.១៦៦ | ៤៤៧.៨៣៦ |
| សំវិធានធនទូទៅ | - | - | - | - |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | - | (៣.៤៦៥) | (១៥.៨៨៩) |
| | ៤៣២.៩៥២ | ២៤៧.៤៦៩ | ១.៧៤៨.៦៩៣ | ១.០០២.៩៩២ |

### (ខ) វិភាគតាមការធានាលើឥណទានដំណើរការ និងមិនដំណើរការ

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ឥណទានស្តង់ដារ ៖ | | | | |
| ឥណទានមានវត្ថុបញ្ចាំ | ៤៣.២៩៥.១៣៣ | ២៤.៧៤៦.៩៦៤ | ១៧៤.៨៦៩.០៤៣ | ១០០.២៩៩.៤៤៦ |
| ឥណទានគ្មានវត្ថុបញ្ចាំ | - | - | - | - |
| ឥណទានក្រោមស្តង់ដារ ៖ | | | | |
| ឥណទានមានវត្ថុបញ្ចាំ | - | - | - | - |
| ឥណទានគ្មានវត្ថុបញ្ចាំ | - | - | - | - |
| | ៤៣.២៩៥.១៣៣ | ២៤.៧៤៦.៩៦៤ | ១៧៤.៨៦៩.០៤៣ | ១០០.២៩៩.៤៤៦ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១១. ឥណទាន និងបុរេប្រទានអតិថិជន (ត)

### (គ) វិភាគតាមអាយុកាល

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ១ខែ | ១.៦១២.០៩៤ | ៩៧៧.៩៩០ | ៦.៥១១.២៤៨ | ២.៣៤០.៩៧២ |
| ២ ខែ ទៅ ៣ ខែ | ៥.៤១៤.៩៤៣ | ១.៨៨៧.៩៨៤ | ២១.៨៦៩.៣៣៩ | ៧.៦៥០.៣៧៨ |
| ៤ ខែ ទៅ ១២ ខែ | ១៩.៩៥៧.៣០៨ | ១៤.១៧៦.២៩៤ | ៨០.៦០៧.៥៦៧ | ៥៧.៤៥៦.៩២០ |
| ១ ទៅ ៥ ឆ្នាំ | ១៥.៧៧៧.៩៨៩ | ៨.១០៥.៤៩៦ | ៦៣.៧២៧.២៩៨ | ៣២.៨៥១.៩៧៦ |
| លើសពី ៥ ឆ្នាំ | ៥៣៣.១៩៩ | - | ២.១៥៣.៩៩១ | - |
| | ៤៣.២៩៥.១៣៣ | ២៤.៧៤៦.៩៦៤ | ១៧៤.៨៦៩.០៤៣ | ១០០.២៩៩.៤៤៦ |

### (ឃ) វិភាគតាមប្រភេទអាជីវកម្ម

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| គ្រឹះស្ថានហិរញ្ញវត្ថុ | ១.៤៩៤.៨៦៨ | ១.០៤៦.០១៧ | ៦.០៣៧.៧៧២ | ៤.២៣៩.៥០៧ |
| ផ្នែកលក់ដុំ និងលក់រាយ | ១៤.៧៣០.៩១៦ | ៦.៧៣៩.៧២៨ | ៥៩.៤៩៨.១៧០ | ២៧.២៩៩.៩០៦ |
| ផ្នែកអចលនទ្រព្យ និងអ្នកអភិវឌ្ឍ | ១២.១០៦.៦០៩ | ៦.៥០៧.៨៨៤ | ៤៨.៨៩៨.៩៩៤ | ២៦.៣៧៦.៤៥៤ |
| ផ្នែកសេវាកម្ម | ៨.៦៨៩.៨៣២ | ៧.៧៦០.៥១៨ | ៣៥.០៩៨.២៣១ | ៣១.៤៥៣.៣៧៩ |
| ផ្នែកផលិតកម្ម | ៤.៦៤៩.៩៨៥ | ១.២៦៦.០០០ | ១៨.៧៨១.២៨៩ | ៥.១៣១.០៩៨ |
| ផ្នែកឧស្សាហកម្មផ្សេងៗ | ១.៦២២.៩២៣ | ១.៤៣០.៨១៧ | ៦.៥៥៤.៩៨៧ | ៥.៧៩៩.១០២ |
| | ៤៣.២៩៥.១៣៣ | ២៤.៧៤៦.៩៦៤ | ១៧៤.៨៦៩.០៤៣ | ១០០.២៩៩.៤៤៦ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១១. ឥណទាន និងបុរេប្រទានអតិថិជន (ត)

### (ខ) វិភាគតាមទំហំធំ និងទំហំតូច

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ទំហំធំ | - | ១.៨៩៧.៧៣៨ | - | ៧.៦៩១.៥៣២ |
| ទំហំតូច | ៤៣.២៩៥.១៣៣ | ២២.៨៤៩.២២៦ | ១៧៤.៨៦៩.០៤៣ | ៩២.៦០៧.៩១៤ |
| | ៤៣.២៩៥.១៣៣ | ២៤.៧៤៦.៩៦៤ | ១៧៤.៨៦៩.០៤៣ | ១០០.២៩៩.៤៤៦ |

ឥណទានធំ កំណត់ដោយធនាគារកណ្តាលជាហានិភ័យឥណទានទូទៅចំពោះអតិថិជនណាមួយដែលលើសពី ១០% នៃមូលនិធិសុទ្ធរបស់ធនាគារ ។

### (ច) អត្រាការប្រាក់

ឥណទាន និងបុរេប្រទានអតិថិជន មានការប្រាក់ប្រចាំឆ្នាំ តាមអត្រាដូចខាងក្រោម :

| | ២០១១ | ២០១០ |
|---|---|---|
| វិបារូបន៍ | ៨,០០% - ១៤,០០% | ១២,០០% - ១៤,០០% |
| ឥណទានមានកាលកំណត់ | ៧% - ២០,០០% | ១០,០០% - ២០,០០% |

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ១២. ទ្រព្យសកម្មផ្សេងៗ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ការប្រាក់ត្រូវទទួលពីឥណទាន និងបុរេប្រទាន អតិថិជន | ២៦២.៥២៩ | ១៥៥.៨៧៦ | ១.០៦០.៣៩៥ | ៦៣១.៧៦៥ |
| ការប្រាក់ត្រូវទទួលពីប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៣៣៨.៣៩៦ | ១៥៦.៧៨៦ | ១.៣៦៦.៧៨១ | ៦៣៥.៤៥៤ |
| ប្រាក់តម្កល់លើការជួលការិយាល័យ និង ផ្ទាំង ផ្សាយពាណិជ្ជកម្ម | ៤៤១.៣៨៩ | ១៤៣.៦៦៤ | ១.៧៨២.៧៧០ | ៥៨២.២៧០ |
| ចំណាយបង់មុន | ២០៩.៦០២ | ១៤៦.៦២៧ | ៨៤៦.៥៨២ | ៥៩៤.២៧៩ |
| ចំណាយបង់មុនលើសេវាកម្មថែទាំផ្សេងៗ | ១៤.៤៨៥ | ១៨.៨៧៩ | ៥៨.៥០៥ | ៧៦.៥១៧ |
| ផ្សេងៗ | ៨៩.៧០៩ | ៣.៧៩៧ | ៣៦២.៣៣៥ | ១៥.៣៨៩ |
| | ១.៣៥៦.១១០ | ៦២៥.៦២៩ | ៥.៤៧៧.៣២៨ | ២.៥៣៥.៦៧៤ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១៣. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ការកែលម្អអគារ | គ្រឿងសង្ហារឹម និង បរិក្ខារភ្ជាប់ | បរិក្ខារកុំព្យូទ័រ | យានយន្ត | សរុប |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១០** | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៤១២.១១២ | ១៥៩.៦៨៦ | ១០៥.៩៥១ | ៦៥.៨២៥ | ៧៤៣.៥៧៤ |
| ការទិញបន្ថែម | ២២.១០៦ | ៣៧.២១៦ | ៥០.៥២១ | ៣.០៤០ | ១១២.៨៨៣ |
| ការធ្វើចំណាត់ថ្នាក់ជាថ្មី | (២៦.៦៧៨) | ២៦.៦៧៨ | - | - | - |
| រំលស់ | (១០១.៣១៦) | (៦៧.០៩១) | (១១៦.៨៩៦) | (២៤.៧៤០) | (៣១០.០៤៣) |
| តម្លៃចុះបញ្ជីសុទ្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | ៣០៦.២២៤ | ១៥៦.៤៨៩ | ៣៩.៥៧៦ | ៤៤.១២៥ | ៥៤៦.៤១៤ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | |
| ថ្លៃដើម | ៥១៨.៣៨៦ | ២៨៩.៧២០ | ៣២០.៦៩៨ | ១០០.៤៧៩ | ១.២២៩.២៨៣ |
| រំលស់បង្គរ | (២១២.១៦២) | (១៣៣.២៣១) | (២៨១.១២២) | (៥៦.៣៥៤) | (៦៨២.៨៦៩) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៣០៦.២២៤ | ១៥៦.៤៨៩ | ៣៩.៥៧៦ | ៤៤.១២៥ | ៥៤៦.៤១៤ |
| *សមមូលជាពាន់រៀល (មិនបានធ្វើសវនកម្ម)* | ១.២៤១.១២៦ | ៦៣៤.២៥០ | ១៦០.៤០២ | ១៧៨.៨៣៩ | ២.២១៤.៦១៧ |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១១** | | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៣០៦.២២៤ | ១៥៦.៤៨៩ | ៣៩.៥៧៦ | ៤៤.១២៥ | ៥៤៦.៤១៤ |
| ការទិញបន្ថែម | ២៧១.៧០៥ | ១២២.៦១១ | ១៩១.៩៤០ | ៣៩.០០០ | ៦២៥.២៥៦ |
| ការជម្រះចេញពីបញ្ជី-សុទ្ធ | - | - | - | (៣.០០៤) | (៣.០០៤) |
| រំលស់ | (១៤៣.២៥៣) | (៨៦.៨៦៩) | (៦៤.៦៥៤) | (២៩.៦០០) | (៣២៤.៣៧៦) |
| តម្លៃចុះបញ្ជីសុទ្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | ៤៣៤.៦៧៦ | ១៩២.២៣១ | ១៦៦.៨៦២ | ៥០.៥២១ | ៨៤៤.២៩០ |
| **ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | | | | | |
| ថ្លៃដើម | ៧៩០.០៩១ | ៤១២.៣៣១ | ៥១២.៦៣៨ | ១២៥.០៦០ | ១.៨៤០.១២០ |
| រំលស់បង្គរ | (៣៥៥.៤១៥) | (២២០.១០០) | (៣៤៥.៧៧៦) | (៧៤.៥៣៩) | (៩៩៥.៨៣០) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ៤៣៤.៦៧៦ | ១៩២.២៣១ | ១៦៦.៨៦២ | ៥០.៥២១ | ៨៤៤.២៩០ |
| *សមមូលជាពាន់រៀល (មិនបានធ្វើសវនកម្ម)* | ១.៧៥៥.៦៥៦ | ៧៧៦.៤២១ | ៦៧៣.៩៥៦ | ២០៤.០៥៤ | ៣.៤១០.០៨៧ |

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ១៤. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ (Moneta) ដុល្លារអាមេរិក | កម្មវិធីកុំព្យូទ័រ (Swift Software) ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១០** | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ៣២២.៩៤៥ | ១២.២៧៦ | ៣៣៥.២២១ |
| បន្ថែម | ៧.៧៦៥ | - | ៧.៧៦៥ |
| រំលស់ | (៨៧.១១៦) | (១២.២៧៦) | (៩៩.៣៩២) |
| តម្លៃចុះបញ្ជីសុទ្ធ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | ២៤៣.៥៩៤ | - | ២៤៣.៥៩៤ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | |
| ថ្លៃដើម | ៤៣៥.៨៩០ | ៣៣.៨៧៥ | ៤៦៩.៧៦៥ |
| រំលស់បង្គរ | (១៩២.២៩៦) | (៣៣.៨៧៥) | (២២៦.១៧១) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | ២៤៣.៥៩៤ | - | ២៤៣.៥៩៤ |
| *សមមូលជាពាន់រៀល (មិនបានធ្វើសវនកម្ម)* | ៩៨៧.២៨៦ | - | ៩៨៧.២៨៦ |
| **គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១១** | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | ២៤៣.៥៩៤ | - | ២៤៣.៥៩៤ |
| បន្ថែម | ១៨.៤០៨ | ៦០.០០០ | ៧៨.៤០៨ |
| រំលស់ | (៨៩.១៩៤) | (៥០០) | (៨៩.៦៩៤) |
| តម្លៃចុះបញ្ជីសុទ្ធ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | ១៧២.៨០៨ | ៥៩.៥០០ | ២៣២.៣០៨ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | | | |
| ថ្លៃដើម | ៤៥៤.២៩៨ | ៩៣.៨៧៥ | ៥៤៨.១៧៣ |
| រំលស់បង្គរ | (២៨១.៤៩០) | (៣៤.៣៧៥) | (៣១៥.៨៦៥) |
| តម្លៃចុះបញ្ជីសុទ្ធ | ១៧២.៨០៨ | ៥៩.៥០០ | ២៣២.៣០៨ |
| *សមមូលជាពាន់រៀល (មិនបានធ្វើសវនកម្ម)* | ៦៩៧.៩៧២ | ២៤០.៣២១ | ៩៣៨.២៩៣ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១៥. ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| គណនីចរន្ត | ១.០២៧ | ២.៩៣១ | ៤.១៤៨ | ១១.៨៧៩ |
| គណនីសន្សំ | ១៧៤.៩២០ | ៨៧.៣៩១ | ៧០៦.៥០២ | ៣៥៤.១៩៦ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ៣០.៤៦២.០៥៥ | ២២.៦០០.០០០ | ១២៣.០៣៦.២៤០ | ៩១.៥៩៧.៨០០ |
| | ៣០.៦៣៨.០០២ | ២២.៦៩០.៣២២ | ១២៣.៧៤៦.៨៩០ | ៩១.៩៦៣.៨៧៥ |

រាល់ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗទាំងអស់ មានកាលកំណត់១ឆ្នាំ។

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ មានដូចខាងក្រោម ៖

| | ២០១១ | ២០១០ |
|---|---|---|
| គណនីចរន្ត | 0% | 0% |
| គណនីសន្សំ | ១,00% - ១,២0% | ១.00% - ១,២0% |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ១,១0% - ៣,00% | 0,៨0% - ៦,៥0% |

## ១៦. ប្រាក់បញ្ញើរបស់អតិថិជន

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| គណនីចរន្ត | ៨៨២.៣៦៥ | ៣៩៩.៧៩១ | ៣.៥៦៣.៨៧២ | ១.៤៥៨.២៣៣ |
| គណនីសន្សំ | ១១.៨៩២.៥៣៧ | ៧.៧៨៦.៥១៥ | ៤៨.០៣៤.១១៩ | ៣១.៥៥៨.៧៤៥ |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ១៦.៥៥៩.០៧១ | ១១.១៩៩.៨៨៨ | ៦៦.៨៨២.០៨៨ | ៤៥.៣៩៣.១៤៦ |
| ប្រាក់បញ្ញើតាមដំណាក់កាល | ៣៥៤.២៥៣ | ១១៧.៧៩០ | ១.៤៣០.៨២៨ | ៤៧៧.៤០៣ |
| | ២៩.៦៨៨.២២៦ | ១៩.៤៦៣.៩៨៤ | ១១៩.៩១០.៩០៧ | ៧៨.៨៨៧.៥២៧ |

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ១៦. ប្រាក់បញ្ញើរបស់អតិថិជន (ត)

អត្រាការប្រាក់ប្រចាំឆ្នាំនៃប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ មានដូចខាងក្រោម :

| | ២០១១ | ២០១០ |
|---|---|---|
| គណនីចរន្ត | - | - |
| គណនីសន្សំ | ០,២០% - ០,៤០% | ១,២០% |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ២,២០% - ៦,៧០% | ២,០០% - ៨,០០% |
| ប្រាក់បញ្ញើតាមដំណាក់កាល | ៣,០០% - ៧,០០% | ៣,០០% - ៧,០០% |

ប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានវិភាគ និងមានអាយុកាល ដូចខាងក្រោម :

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| រយៈពេលក្រោម ១ឆ្នាំ | ២៩.៤៦៩.០២១ | ១៩.៤៦៣.៩៨៤ | ១១៩.០២៥.៣៧៦ | ៧៨.៨៨៧.៩២៧ |
| ១ឆ្នាំ ទៅ ៥ឆ្នាំ | ២១៩.២៤៥ | - | ៨៨៥.៩៣១ | - |
| | ២៩.៦៨៨.២៦៦ | ១៩.៤៦៣.៩៨៤ | ១១៩.៩១០.៩០៧ | ៧៨.៨៨៧.៩២៧ |

### ១៧. បង្គរ និងទ្រព្យអកម្មផ្សេងៗ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ការប្រាក់ត្រូវបង់ | ៦១៦.២៩៤ | ៦២៣.១៣២ | ២.៤៨៩.២១១ | ២.៥២៥.៥៥៤ |
| បង្គរ និងទ្រព្យអកម្មផ្សេងៗ | ៤៧.៤៣៦ | ៣៥.២៤២ | ១៩១.៥៩៦ | ១៤២.៨៣៨ |
| | ៦៦៣.៧៣០ | ៦៥៨.៣៧៤ | ២.៦៨០.៨០៧ | ២.៦៦៨.៣៩២ |

រាល់បង្គរ និងទ្រព្យអកម្មផ្សេងៗទាំងអស់ នឹងត្រូវទូទាត់ក្នុងរយៈពេល១ឆ្នាំ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១៨. ដើមទុន

បម្រែបម្រួលដើមទុនមានដូចខាងក្រោម :

| | ២០១១ | ២០១០ | ២០១១ | ២០១០ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| | | | (មិនបានធ្វើសវនកម្ម) | (មិនបានធ្វើសវនកម្ម) |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ | ១៥.០០០.០០០ | ១៥.០០០.០០០ | ៦០.៧៩៥.០០០ | ៦២.៥៣៥.០០០ |
| ដើមទុនបន្ថែមក្នុងឆ្នាំ | ២៤.០០០.០០០ | - | ៩៦.៩៣៦.០០០ | - |
| លំអៀងពីការប្តូររូបិយប័ណ្ណ | - | - | (២១០.០០០) | (១.៧៤០.០០០) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | ៣៩.០០០.០០០ | ១៥.០០០.០០០ | ១៥៧.៥២១.០០០ | ៦០.៧៩៥.០០០ |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ចំនួនភាគហ៊ុនដែលបានចុះបញ្ជីរបស់ធនាគារមានចំនួន ៣៩.០០០ភាគហ៊ុន (២០១០: ១៥.០០០ ភាគហ៊ុន) ដែលមានតម្លៃ ១.០០០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន (២០១០ : ១.០០០ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន)។

| ភាគទុនិក | ២០១១ | | | ២០១០ | | |
|---|---|---|---|---|---|---|
| | ចំនួនភាគហ៊ុន | % | ដុល្លារអាមេរិក | ចំនួនភាគហ៊ុន | % | ដុល្លារអាមេរិក |
| SBI Holdings, Inc. | ១៥.៦០០ | ៤០,០០% | ១៥.៦០០.០០០ | ៦.០០០ | ៤០,០០% | ៦.០០០.០០០ |
| Hidy Investment Co., Ltd. | ១៥.៤៣៥ | ៣៩,៥៧% | ១៥.៤៣៥.០០០ | ១.៤៨៥ | ៩,៩០% | ១.៤៨៥.០០០ |
| Hyundai Swiss I Savings Bank | ១.៤៨៥ | ៣,៨១% | ១.៤៨៥.០០០ | ១.៤៨៥ | ៩,៩០% | ១.៤៨៥.០០០ |
| Hyundai Swiss II Savings Bank | ១.៤៨៥ | ៣,៨១% | ១.៤៨៥.០០០ | ១.៤៨៥ | ៩,៩០% | ១.៤៨៥.០០០ |
| Kyung Ki Growth and Development Co., Ltd | ១.៤៨៥ | ៣,៨១% | ១.៤៨៥.០០០ | ១.៤៨៥ | ៩,៩០% | ១.៤៨៥.០០០ |
| Kim Kwang Jin | ១.៤៨៥ | ៣,៨១% | ១.៤៨៥.០០០ | ១.៤៨៥ | ៩,៩០% | ១.៤៨៥.០០០ |
| Kim Jong Min | ១.១២៥ | ២,៨៨% | ១.១២៥.០០០ | ១.១២៥ | ៧,៥០% | ១.១២៥.០០០ |
| Mirae Credit Information Service Corp | ៩០០ | ២,៣១% | ៩០០.០០០ | ៤៥០ | ៣,០០% | ៤៥០.០០០ |
| | ៣៩.០០០ | ១០០% | ៣៩.០០០.០០០ | ១៥.០០០ | ១០០% | ១៥.០០០.០០០ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ១៩. ទ្រព្យអកម្មយថាហេតុ និងកិច្ចសន្យាផ្សេងៗ

### ក) កិច្ចសន្យាឥណទាន ការធានា និងឥណទានហិរញ្ញវត្ថុផ្សេងៗ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ឥណទានបានអនុម័ត ប៉ុន្តែមិនទាន់ផ្តល់ទៅឱ្យអតិថិជន | ១.១៥៣.៥០០ | - | ៤.៦៥៨.៩៨៧ | - |
| ចំណែកនៃឥណទានវិបារូបន៍ដែលមិនបាន ប្រើប្រាស់ | ១.០៤១.២៤៣ | ១.៤៩២.០០៤ | ៤.២០៥.៥៨០ | ៦.០៤៧.០៩២ |
| លិខិតធនាគារ | ៣.២៦៨.៦៣១ | ១.២១៣.៩៦១ | ១៣.២០២.០០១ | ៤.៩២០.១៨៤ |
| | ៥.៤៦៣.៣៧៤ | ២.៧០៥.៩៦៥ | ២២.០៦៦.៥៦៨ | ១០.៩៦៧.២៧៦ |

កិច្ចសន្យាខាងលើ ត្រូវគេរំពឹងថាត្រូវបានប្រើប្រាស់ និងទូទាត់ទាំងស្រុងក្នុងរយៈពេល១ឆ្នាំ។

### ខ) កិច្ចសន្យាភតិសន្យាប្រតិបត្តិ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ធនាគារមានកិច្ចសន្យាភតិសន្យាដែលមិនអាចលុបចោលបាន ដូចខាងក្រោមៈ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ១ ឆ្នាំ | ៣០១.៥៧២ | ១៨៩.៦០០ | ១.២១៨.០៤៩ | ៧៦៨.៤៤៩ |
| ២ ឆ្នាំ ទៅ ៥ ឆ្នាំ | ៧៤៦.៩៤៦ | ៥១៧.៧៥០ | ៣.០១៦.៩១៥ | ២.០៩៨.៤៤១ |
| លើសពី ៥ឆ្នាំ | ៥២២.៧៦០ | ៣៣៦.០០០ | ២.១១១.៤២៨ | ១.៣៦១.៨០៨ |
| | ១.៥៧១.២៧៨ | ១.០៤៣.៣៥០ | ៦.៣៤៦.៣៩២ | ៤.២២៨.៦៩៨ |

## ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

### ២០. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៤.២៩៧.២២៨ | ២.២៣៩.៨៣៦ | ១៧.១៩៤.៩៤៤ | ៩.០៦១.៨៤៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ | | | | |
| និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | | | |
| គណនីចរន្ត | ២.៣៥៤.៧២២ | ៣.០៦៣.០៨៥ | ៩.៥១០.៧២២ | ១២.៤១៤.៦៨៤ |
| គណនីសន្សំ | ១.៤១៨.៨១៣ | ១.៧៧២.៥០៣ | ៥.៧៣០.៥៨៦ | ៧.១៨៣.៩៥៥ |
| គណនីប្រាក់បញ្ញើមានកាល | | | | |
| កំណត់ (តិចជាង៣ខែ) | ១០.៥០០.០០០ | ៨.០០០.០០០ | ៤២.៤០៩.៥០០ | ៣២.៤២៤.០០០ |
| សមតុល្យនៅធនាគារកណ្តាល | | | | |
| គណនីចរន្ត | ៥.២៩៣.៧៦៩ | ២.៥២៧.២៣៧ | ២១.៣៨១.៥៣៣ | ១០.២៤២.៨៩២ |
| | ២៣.៨២៤.៥៣២ | ១៧.៥៩៨.៦៦១ | ៩៦.២២៧.២៨៥ | ៧១.៣២៧.៣៧៤ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២១. សាច់ប្រាក់ បានពីសកម្មភាពប្រតិបត្តិការ

| | ២០១១ ដុល្លារអាមេរិក | ២០១០ ដុល្លារអាមេរិក | ២០១១ ពាន់រៀល (មិនបានធ្វើសវនកម្ម) | ២០១០ ពាន់រៀល (មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនបង់ពន្ធ | ១.៦៧៧.១៩៥ | ៧២៨.១៧៤ | ៦.៧៧៤.១៨៨ | ២.៩៥១.២៨៨ |
| *និយ័តកម្មសម្រាប់ខ្ទង់មិនមែនសាច់ប្រាក់ :* | | | | |
| សំវិធានធនឥណទាន និងបុរេប្រទានអតិថិជន អាក្រក់ និងសង្ស័យ (កំណត់សម្គាល់ ១១.ក) | ១៨៥.៤៨៣ | ១១០.៤៩៥ | ៧៤៩.១៦៦ | ៤៤៧.៨៣៦ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់ ១៣) | ៣២៤.៣៧៦ | ៣១០.០៤៣ | ១.៣១០.១៩៥ | ១.២៥៦.៦០៤ |
| រំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ១៤) | ៨៩.៦៩៤ | ៩៩.៣៩២ | ៣៦២.២៧៤ | ៤០២.៨៣៦ |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | (៤៩៤) | - | (១.៩៩៥) | - |
| ចំណូលការប្រាក់សុទ្ធ | (៣.២៣៥.១៨៣) | (១.៩១៨.១៣៥) | (១៣.០៦៦.៩០៣) | (៧.៧៧៤.២០១) |
| | (៩៥៨.៩២៩) | (៦៧០.០៣១) | (៣.៨៧៣.១១៥) | (២.៧១៥.៦៣៧) |
| កំណើនឥណទាន និងបុរេប្រទានអតិថិជន | (១៨.៥៤៨.១៦៩) | (១១.៩៤៩.៥៧២) | (៧៤.៩១៦.០៥៥) | (៤៨.៤៣១.៦១៥) |
| កំណើនទ្រព្យសកម្មផ្សេងៗ | (៤៤២.២១៧) | (១៩៣.៤១២) | (១.៧៨៦.១១៤) | (៧៨៣.៨៩៩) |
| កំណើនប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ៧.៩៤៧.៦៨០ | ៨.៥៤៥.៤១០ | ៣២.១០០.៦៨០ | ៣៤.៦៣៤.៥៤៧ |
| កំណើនប្រាក់បញ្ញើរបស់អតិថិជន | ១០.២២៤.២៨២ | ១៤.៤៨៥.៦៩០ | ៤១.២៩៥.៨៧៥ | ៥៨.៧១០.៥០២ |
| កំណើនបង្គរ និងទ្រព្យអកម្មផ្សេងៗ | ១២.១៩៦ | ១២.២៥១ | ៤៩.២៦០ | ៤៩.៦៥៣ |
| ការប្រាក់បានទទួល | ៤.២៧២.៦០៤ | ២.៨២៧.៣៤២ | ១៧.២៥៧.០៤៨ | ១១.៤៥៩.២១៧ |
| ការប្រាក់បានបង់ | (១.៣៣២.៥២៣) | (៥០៥.៤៦៦) | (៥.៣៨២.០៦០) | (២.០៤៨.៦៥៤) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (១៥៣.៨៨៥) | (៣៥.០៩០) | (៦២១.៥៤២) | (១៤២.២២០) |
| **លំហូរសាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | **១.០២១.០៣៩** | **១២.៥១៧.១២២** | **៤.១២៣.៩៧៧** | **៥០.៧៣១.៨៩៤** |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២២. សមតុល្យ និងប្រតិបត្តិការភាគីសម្ព័ន្ធញាតិ

នៅក្នុងដំណើរការអាជីវកម្មធម្មតា ធនាគារបានធ្វើប្រតិបត្តិការមួយចំនួនជាមួយភាគីសម្ព័ន្ធញាតិ។ ទំហំនៃប្រតិបត្តិការជាមួយភាគីសម្ព័ន្ធញាតិ សមតុល្យដែលមិនទាន់ទូទាត់គិតត្រឹមដំណាច់ឆ្នាំ និងចំណូល-ចំណាយពាក់ព័ន្ធផ្សេងៗក្នុងឆ្នាំនេះ មានដូចខាងក្រោម ៖

### ក) ឥណទាន និងបុរេប្រទានអតិថិជន

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ឥណទាន និងបុរេប្រទានអតិថិជន - បុគ្គលិក | ១១០.៨៤៩ | - | ៤៤៧.៧១៩ | - |
| ចំណូលការប្រាក់ | ២.៥៩២ | - | ១០.៤៦៩ | - |

### ខ) ប្រាក់បញ្ញើរបស់សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងសំខាន់ៗ

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ប្រាក់បញ្ញើរបស់បុគ្គលិក | ២២.៨៦៣ | ២៣.៥៨៥ | ៩២.៣៤៤ | ៩៥.៥៩០ |
| ចំណាយការប្រាក់លើប្រាក់បញ្ញើ | ៣១៧ | ១២៦ | ១.២៨០ | ៥១១ |

### គ) ការទូទាត់ជូនគណៈគ្រប់គ្រងសំខាន់ៗ

| | ២០១១<br>ដុល្លារអាមេរិក | ២០១០<br>ដុល្លារអាមេរិក | ២០១១<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) | ២០១០<br>ពាន់រៀល<br>(មិនបានធ្វើសវនកម្ម) |
|---|---|---|---|---|
| ប្រាក់បៀវត្ស និងអត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ (គណៈគ្រប់គ្រងសំខាន់ៗ) | ៥០២.៤៣២ | ៣២៧.៤៧០ | ២.០២៩.៣២៣ | ១.៣២៧.២៣៦ |

# ធនាគារ ភ្នំពេញ ពាណិជ្ជ
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពរបស់ធនាគារ ប្រឈមមុខនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួនដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យរូបិយវត្ថុ ហានិភ័យអត្រាការប្រាក់ និងហានិភ័យតម្លៃ) និងហានិភ័យសាច់ប្រាក់ងាយស្រួល។ ចំពោះអាជីវកម្មហិរញ្ញវត្ថុ គឺជាចម្បងទទួលយកនូវហានិភ័យ ហើយហានិភ័យប្រតិបត្តិការគឺជាផលវិបាកដែលពិបាកចៀសរួចណាស់ក្នុងដំណើរការអាជីវកម្ម។

ធនាគារ មិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុជាប់លក្ខខណ្ឌ (derivative financial instrument) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ និងការផ្តោះប្តូរអត្រាការប្រាក់ (interest rate swaps) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួនទេ។

### ២៣.១ ហានិភ័យឥណទាន

ធនាគារប្រឈមមុខនឹងហានិភ័យឥណទាន ជាហានិភ័យដែលសមភាគីធ្វើឱ្យធនាគារមានការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារមិនបានបំពេញកាតព្វកិច្ចសងបំណុលជូនធនាគារវិញ។ ហានិភ័យឥណទាន គឺជាហានិភ័យដែលមានសារសំខាន់ជាងគេបំផុតក្នុងអាជីវកម្មធនាគារ។ ហានិភ័យឥណទាន ច្រើនតែកើតមកពីការផ្តល់ឥណទាន និងបុរេប្រទាន។ ហានិភ័យឥណទានក៏មាននៅក្នុងឧបករណ៍ហិរញ្ញវត្ថុនៃខ្ទង់ក្រៅតារាងតុល្យការដែរ ដូចជាកិច្ចសន្យាឥណទានជាដើម។ ការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានអនុវត្តដោយគណៈកម្មាធិការឥណទានរបស់ធនាគារ។

#### ក. ការវាស់ស្ទង់ហានិភ័យឥណទាន

ហានិភ័យឥណទាន ត្រូវបានគ្រប់គ្រងតាមរយៈការវិភាគជាប្រចាំទៅលើលទ្ធភាពរបស់កូនបំណុល និងកូនបំណុលសំខាន់ៗ ក្នុងការបំពេញកាតព្វកិច្ចសងការប្រាក់ និងប្រាក់ដើម។ ហានិភ័យឥណទាន ក៏ត្រូវបានគ្រប់គ្រងជាផ្នែក តាមរយៈការទទួលវត្ថុបញ្ចាំ និងការធានាជាលក្ខណៈបុគ្គល។ គណៈគ្រប់គ្រង ធ្វើការវាយតម្លៃឥណទានប្រចាំឆ្នាំ បន្ទាប់ពីផ្តល់ឥណទាន និងបុរេប្រទានឱ្យអតិថិជនរួចហើយ ដើម្បីវិភាគអំពីស្ថានភាពហិរញ្ញវត្ថុ និងការសងប្រាក់របស់កូនបំណុល។

#### ខ. ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍កាត់បន្ថយហានិភ័យ

ធនាគារធ្វើប្រតិបត្តិការ និងផ្តល់ឥណទាន និងបុរេប្រទានឱ្យឯកត្តជន ឬសហគ្រាសផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារគ្រប់គ្រងលើកម្រិត និងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាន នៅពេលដែលវាត្រូវបានគេរកឃើញ។ ហានិភ័យធំ ត្រូវបានកំណត់ដោយធនាគារកណ្តាល ថាជាហានិភ័យឥណទានទូទៅដែលបានផ្តល់ឱ្យឯកត្តជនណាមួយលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

# ធនាគារ ភ្នំពេញ ពាណិជ្ជ
# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

## ២៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ២៣.១ ហានិភ័យឥណទាន (ត)

#### ខ. ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍កាត់បន្ថយហានិភ័យ (ត)

យោងតាមលក្ខខណ្ឌរបស់ប្រកាសលេខ ធ៧-០៦-២២៦ប្រ.ក. របស់ធនាគារកណ្តាល តម្រូវឱ្យធនាគាររក្សាគ្រប់ពេលវេលានូវអនុបាតអតិបរមាចំនួន ២០% រវាងហានិភ័យឥណទានទូទៅរបស់ធនាគារ ធៀបនឹងអតិថិជនជាឯកត្តជន និងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ហានិភ័យឥណទានធំសរុបមិនត្រូវលើសពី ៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារនោះទេ។

ធនាគារប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ គោលការណ៍ដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងនោះ គឺការធានាដោយការដាក់វត្ថុបញ្ចាំលើឥណទាន និងបុរេប្រទានអតិថិជន ដែលជាការអនុវត្តទូទៅមួយ។ ធនាគារអនុវត្តគោលការណ៍ ស្តីពីការទទួលយកបាននូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ ដើម្បីធានាឥណទាន និងបុរេប្រទានអតិថិជនមានដូចជា :

- វត្ថុបញ្ចាំជាទ្រព្យសម្បត្តិសម្រាប់តាំងទីលំនៅដ្ឋាន (មានដូចជា ដីធ្លី អគារ និងទ្រព្យសម្បត្តិផ្សេងៗ)
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើមានលក្ខខណ្ឌ ប្រសិនបើមាន ។

#### គ. គោលការណ៍សំវិធានធន និងការថយចុះតម្លៃ

